កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយ

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

# ប័ណ្ណព័ត៌មាន អំពីសកម្មភាពរបស់កម្មវិធី DAR នៅក្នុងការទារកំណែទម្រង់វិមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ













**ចេញផ្សាយដោយ៖**
Deutsche Gesellschaft für
Internationale Zusammenarbeit (GIZ) GmbH

ការិយាល័យចុះឈ្មោះនៅទីក្រុងបោន និងអេចបន ប្រទេសអាល្លឺម៉ង់
ការិយាល័យភ្នំពេញរបស់ជី អាយ ហ្សិត

វិមានការិយាល័យអូវល
អាគារលេខ១ ជាន់ទី១០ ផ្លូវលេខ៣៦០ ប្រអប់សំបុត្រលេខ៨១ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរសព្ទ៖ + ៨៥៥ (២៣) ៨៦០ ១១០
giz-kambodscha@giz.de
www.giz.de/kambodscha

អត្ថបទ និងទទួលខុសត្រូវដោយ៖
កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវដ្ឋបាល (DAR)

រៀបចំ និងរចនាដោយ ៖
កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (DAR)

រូបភាពដោយ៖ GIZ/DAR

រាជធានីភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០២២

giz

# ប័ណ្ណព័ត៌មាន៖ ការចូលរួមរបស់ប្រជាពលរដ្ឋ

## ១. តើការចូលការចូលរួមរបស់ប្រជាពលរដ្ឋគឺជាអ្វី?

ការចូលរួមរបស់ប្រជាពលរដ្ឋ សំដៅលើការចូលរួមរបស់ប្រជាពលរដ្ឋដែលធ្វើឱ្យការផ្តល់សេវាសាធារណៈ មានភាពប្រសើរឡើង ក្នុងគោលដៅលើកកម្ពស់គុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។ នៅក្នុងប្រទេសកម្ពុជា ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាមធ្យោបាយដ៏សំខាន់មួយដែលសមាជិកក្រុមប្រឹក្សាជាប់ឆ្នោត ទទួលបាននូវព័ត៌មានស្តីអំពីតម្រូវការរបស់ប្រជាពលរដ្ឋ មតិកែលម្អ និងធាតុចូលផ្សេងៗទៀតក្នុងអំឡុងពេលនៃការរៀបចំផែនការ ការអនុវត្ត និងការត្រួតពិនិត្យតាមដានការអនុវត្តសកម្មភាព ព្រមទាំងទទួលបានការគាំទ្រក្នុងការធ្វើសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា[1]។ ជានិច្ចកាល ប្រជាពលរដ្ឋតែងតែបង្កើតជាក្រុមក្នុងទម្រង់ផ្សេងៗគ្នា ដូចជា សមាគមន៍ ក្រុមសហគមន៍ អង្គការសហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលជាទូទៅគេហៅដោយខ្លីថា អង្គការសង្គមស៊ីវិល(CSOs)។ អង្គការសង្គមស៊ីវិលទាំងនេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងការពារផលប្រយោជន៍សេដ្ឋកិច្ច សង្គមកិច្ច វិទ្យាសាស្ត្រ វប្បធម៌ បរិស្ថាន និងសាសនា[2]។ ជាទូទៅ ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយអង្គការសង្គមស៊ីវិល ដែលពាក់ព័ន្ធនឹងការផ្តល់សេវា ជាពិសេសសេវាសង្គមក្នុងវិស័យសុខាភិបាល ឬ វិស័យអប់រំ មានភាពល្អប្រសើរ។ ចំណែកឯទំនាក់ទំនងរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងអង្គការសង្គមស៊ីវិលដែលធ្វើការក្នុងវិស័យទាក់ទងនឹងការតស៊ូមតិ សិទ្ធិមនុស្ស សេរីភាពសារព័ត៌មាន តែងតែជួបផលលំបាក។

ជាប្រពៃណី ប្រទេសកម្ពុជាមានតែសមាគមន៍សាសនា ដែលស្ម័គ្រចិត្តផ្តល់សេវាសង្គម និងជំនួយមនុស្សធម៌។ ក្រោយមកក្នុងរវាងឆ្នាំ១៩៩១ និង១៩៩៣ ទស្សនៈនៃអង្គការសង្គមស៊ីវិល រួមទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការសហគមន៍មូលដ្ឋាន ឬ បណ្តាញអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនានា (NGO-network) ត្រូវបានបង្កើតឡើង នៅក្នុងសម័យអ៊ុនតាក់។ ភាគច្រើននៃអង្គការសង្គមស៊ីវិលទាំងនេះ ធ្វើការលើវិស័យដែលទាក់ទងនឹងការតស៊ូមតិ សិទ្ធិមនុស្ស ការផ្តល់សេវានានា និងការផ្តល់ជាជំនួយមនុស្សធម៌។ ពួកគេអាចធ្វើការងារទាំងនោះបាន ភាគច្រើនអាស្រ័យទៅលើលទ្ធភាពទទួលបានមូលនិធិពីម្ចាស់ជំនួយអន្តរជាតិ។ លើសពីនេះទៀត អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយចំនួន បាននឹងកំពុងធ្វើការអនុវត្តលើវិស័យទាំងនេះនៅប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ១៩៩១មក រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍បានទទួលស្គាល់នូវតួនាទីដ៏សំខាន់របស់អង្គការសង្គមស៊ីវិល និងការរួមចំណែករបស់ពួកគេក្នុងកម្មវិធីស្តារ អភិវឌ្ឍន៍ និងកំណែទម្រង់នៅកម្ពុជា។

នៅក្នុងប្រទេសកម្ពុជានាចន្លោះឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៩ មានអង្គការមិនមែនរដ្ឋាភិបាល និងសមាគមន៍ចំនួន ៥.៣៨៦ ដែលបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ ក្នុងចំណោមនោះ រួមមាន ៣.២៥១ ជាអង្គការមិនមែនរដ្ឋាភិបាល និង

[1] ធានាគារពិភពលោក៖ គណនេយ្យភាពសង្គមក្នុងការផ្តល់សេវាសាធារណៈ ឆ្នាំ២០០៤ និង លេខាធិការដ្ឋាន គ.ជ.អ.ប៖ ឯកសារបច្ចេកទេស ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋ ឆ្នាំ២០១៤

[2] លេខាធិការដ្ឋាន គ.ជ.អ.ប៖ ឯកសារបច្ចេកទេស ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋ ទំព័រ ៩

២.១៣៥ ជាអង្គការសមាគមន៍។ ទោះយ៉ាងណាក៏ដោយ ស្ថិតិរបស់ក្រសួងមហាផ្ទៃបានបង្ហាញថា អង្គការសង្គមស៊ីវិលចំនួនតែ ២.០០០ តែប៉ុណ្ណោះ ដែលនៅបន្តដំណើរការអនុវត្តសកម្មភាពយ៉ាងសកម្មនៅក្នុងប្រទេសកម្ពុជា[3]។

## ២. ស្ថានភាពជាក់ស្តែង និងតួលេខ

- វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សា បានផ្តល់ឱកាសឱ្យប្រជាពលរដ្ឋបានចូលរួម ដើម្បីទទួលបានព័ត៌មាន និងពិភាក្សាលើរបាយការណ៍របស់ក្រុមប្រឹក្សា និងលើកជាអនុសាសន៍ ឬសំណើនានាទៅដល់ក្រុមប្រឹក្សាសម្រាប់ធ្វើការពិភាក្សាបន្ថែមទៀត។ រាជរដ្ឋាភិបាល មានគោលបំណងលើកកម្ពស់ការទទួលខុសត្រូវ និងពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈរបស់រដ្ឋាភិបាលមូលដ្ឋាន ដោយពិចារណាទៅលើតម្រូវការដែលបានលើកឡើងដោយផ្ទាល់ពីប្រជាពលរដ្ឋ និងតាមរយៈអង្គការសង្គមស៊ីវិល។ វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សា គឺជាយន្តការគណនេយ្យភាពដ៏សំខាន់របស់រដ្ឋាភិបាលក្នុងការអនុវត្តអភិបាលកិច្ចមូលដ្ឋាន។ ជាក់ស្តែងនៅខេត្តបាត់ដំបង ចំនួនអ្នកចូលរួមក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ ដែលរួមទាំងជនពិការ និងអង្គការសង្គមស៊ីវិលផងនោះ មានការកើនឡើងប្រមាណ ២២៨% បើប្រៀបធៀបលទ្ធផលនៃការចូលរួមរបស់ប្រជាពលរដ្ឋ រវាងឆ្នាំ២០១៧ (១.២៨៣នាក់ ក្នុងនោះមាន ស្រ្តី ៣៧៦ នាក់) និងឆ្នាំ២០១៩ (៤.២០៩ នាក់ ស្រ្តី ១.៤៧៧ នាក់)។ ទោះបីជាមានផលប៉ះពាល់ដោយសារជំងឺកូវីត-១៩ ក្នុងឆ្នាំ២០២០ ក៏ដោយ ចំនួនអ្នកចូលរួមសរុបនៅក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សា នៅតែមានកម្រិតខ្ពស់ជាងឆ្នាំ២០១៧ គឺមានអ្នកចូលរួមចំនួន ២.១៤៥ នាក់ ដែលមានស្រ្តីចំនួន ៧០១ នាក់។
- នៅក្នុងខេត្តបាត់ដំបង ចាប់តាំងពីឆ្នាំ២០១៩ ដល់ឆ្នាំ២០២០ សមាជិកអង្គការសង្គមស៊ីវិលចំនួន ១៣០ នាក់ (ស្រ្តី ៣៦ នាក់) បានចូលរួមជាទៀងទាត់ក្នុងកិច្ចប្រជុំបណ្តាញប្រចាំត្រីមាសរបស់ពួកគេ ដើម្បីផ្លាស់ប្តូរព័ត៌មាន ពិភាក្សាអំពីយុទ្ធសាស្រ្តនៃការតស៊ូមតិ និងកំណែទម្រង់រចនាសម្ព័ន្ធ និងមុខងាររបស់បណ្តាញអង្គការសង្គមស៊ីវិល។
- នៅក្នុងខេត្តបាត់ដំបង គិតត្រឹមខែឧសភា ឆ្នាំ២០២១ សមាជិកអង្គការសម្ព័ន្ធភាពជាដៃគូដើម្បីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យហៅកាត់ថា CPDD បានចូលរួមកិច្ចប្រជុំសំខាន់ៗចំនួនពីរគឺ (១) កិច្ចប្រជុំភាពជាដៃគូរវាងរដ្ឋបាលខេត្ត និងអង្គការសង្គមស៊ីវិល និង (២) កិច្ចប្រជុំក្រុមការងារនៃការិយាល័យប្រជាពលរដ្ឋ រវាងរដ្ឋបាលខេត្ត និងអង្គការសង្គមស៊ីវិល ដែលមានអ្នកចូលរួមប្រមាណ ៣៣០ នាក់ (ស្រី ១៥៦ នាក់)។ គោលបំណងនៃកិច្ចប្រជុំទាំងពីរនេះ គឺដើម្បីពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅមូលដ្ឋាន និងពង្រឹងសំឡេងរបស់អង្គការសង្គមស៊ីវិលក្នុងការរៀបចំគោលនយោបាយ និងបញ្ហានានាទាក់ទងនឹងការអភិវឌ្ឍ។
- នៅថ្នាក់ជាតិ ក្នុងកិច្ចខិតខំប្រឹងប្រែងធ្វើការបញ្ចុះបញ្ចូល និងតស៊ូមតិ លេខាធិការរបស់ CPDD បានចូលរួមក្នុងកិច្ចប្រជុំ និងវេទិកានានាជាច្រើន ដូចជា កិច្ចប្រជុំជាមួយក្រុមការងារថវិកាជាតិនៃអង្គការសង្គមស៊ីវិល (CSO-BWG) កិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិលនានាស្តីពីផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ (NSDP) សម្រាប់ឆ្នាំ២០១៩-២០២៣

[3] ផ្អែកលើរបាយការណ៍របស់អ្នកនាំពាក្យរបស់ក្រសួងមហាផ្ទៃ នៅក្នុងវេទិការភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដែលរៀបចំនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១៩ និងចុះផ្សាយលើកាសែតភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩

សន្និសីទស្តីពីសិទ្ធិទទួលបានព័ត៌មានសម្រាប់ទាំងអស់គ្នា កិច្ចប្រជុំរៀបចំថវិការដ្ឋបាលថ្នាក់ក្រោមជាតិ កិច្ចប្រជុំស្តីពីសម្បទានដីសេដ្ឋកិច្ច (ELC) និងកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី ២ (NP-2)។

- ក្នុងឆ្នាំ២០២០ បុគ្គលិកនៃរដ្ឋបាល និងសមាជិកក្រុមប្រឹក្សា ក្រុង ស្រុក គោលដៅទាំងប្រាំពីររបស់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវដ្ឋបាល(DAR) រួមមានបុរស ចំនួន១២៧នាក់ និងស្ត្រី ចំនួន៣៤ នាក់ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលបន្ថែមស្តីពីឯកសារបច្ចេកទេសរបស់រដ្ឋាភិបាលស្តីពីការពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋ។
- នៅក្នុងឆ្នាំ២០២១ ដោយពិគ្រោះយោបល់ជាមួយសមាជិក CPDD កម្មវិធី DAR បានធ្វើការស្ទង់មតិជាមួយអង្គការសង្គមស៊ីវិលនៅខេត្តបាត់ដំបង ដើម្បីស្វាបស្ទង់មតិលើការពេញចិត្តរបស់ពួកគេលើយន្តការនៃការចូលរួមរបស់ប្រជាពលរដ្ឋដែលមានស្រាប់នៅថ្នាក់ក្រុង ស្រុក ឃុំ។ លទ្ធផលនៃការស្ទង់មតិបានរកឃើញថាប្រមាណ ពី ៦៥% ទៅ ៨០% នៃអ្នកបានចូលរួមឆ្លើយសំណួរ បានពេញចិត្តនឹងការឆ្លើយតបរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះកង្វល់នានាដែលលើកឡើងដោយប្រជាពលរដ្ឋទាក់ទងនឹងការផ្តល់សេវារដ្ឋបាល សុខាភិបាល និងអប់រំ។

អង្គការសម្ព័ន្ធភាពជាដៃគូដើម្បីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យហៅកាត់ថា CPDD គឺជាបណ្តាញនៃអង្គការមិនមែនរដ្ឋាភិបាល ដែលលើកកម្ពស់សំឡេងសមូហភាព និងការចូលរួមប្រកបដោយអត្ថន័យរបស់សង្គមស៊ីវិលជាមួយរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងការអភិវឌ្ឍន៍លទ្ធិប្រជាធិបតេយ្យនៅកម្ពុជាដែលមានសមាជិតជាង១០០អង្គការ។



*កិច្ចប្រជុំបណ្តាញអង្គការសង្គមស៊ីវិល (NGO Network) នៅខេត្តបាត់ដំបង (រូបភាព៖ CPDD)*

## ៣. ការគាំទ្ររបស់ GIZ

- កម្មវិធី EU-DAR (២០១៦-២០១៩)

ក្នុងពេលអនុវត្តកម្មវិធី EU-DAR (ដែលជាកម្មវិធីមុនរបស់កម្មវិធី DAR បច្ចុប្បន្ន ដែលទទួលបានសហហិរញ្ញប្បទានពីសហភាពអឺរ៉ុប) លេខាធិការដ្ឋាន គ.ជ.អ.ប (NCDD-S) បានរៀបចំសិក្ខាសាលាចែករំលែកចំណេះដឹង និងចងក្រងបណ្តាញសម្រាប់សមាជិកក្រុមប្រឹក្សាស្ត្រីមកពីថ្នាក់ខេត្ត ក្រុង និងស្រុក។ លើសពីនេះ វគ្គបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាស្ត្រីទូទាំង

ប្រទេស ត្រូវបានផ្តល់ជាបន្តបន្ទាប់ដោយអង្គការសង្គមស៊ីវិលចំនួន៥ រួមមាន វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API), VBNK, អង្គការសីលការ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C) និងអង្គការស្តារកម្ពុជា ពីព្រោះក្រុមប្រឹក្សាស្ត្រីជាច្រើននាក់ដែលទើបជាប់ឆ្នោតថ្មី មិនទាន់មានបទពិសោធន៍ក្នុងការបំពេញការងាររបស់គេក្នុងនាមជាក្រុមប្រឹក្សា។

- **កម្មវិធី DAR បច្ចុប្បន្ន (ឧសភា ២០១៩ - មេសា ២០២២) មានសកម្មភាពសំខាន់ៗ ដូចខាងក្រោម៖**

| ថ្នាក់ជាតិ | |
|---|---|
| | • សហការណ៍ជាមួយរដ្ឋាភិបាលដើម្បីឱ្យអង្គការសង្គមស៊ីវិលបានចូលរួម និងទទួលស្គាល់ជំនាញរបស់ពួកគេ ដូចជាចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចពាក់ព័ន្ធ និងក្នុងការរៀបចំផែនការ ការអនុវត្ត ការត្រួតពិនិត្យតាមដានជាដើម។<br>• ការសម្របសម្រួលឱ្យមានការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងការរៀបចំកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី ២<br>• សហការជាមួយក្រសួងមុខងារសាធារណៈ (MCS) ក្នុងការតាក់តែងសេចក្តីណែនាំស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋនៅថ្នាក់ជាតិ<br>• ការផ្តល់ប្រឹក្សាបច្ចេកទេស និងការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ CPDD ដែលជាអង្គការឆ័ត្ររបស់អង្គការជាតិដែលចូលរួមយ៉ាងសកម្មក្នុងដំណើរការអនុវត្តកំណែទម្រង់វិមជ្ឈការ។<br>• ចូលរួមផ្លាស់ប្តូរយោបល់ជាទៀងទាត់ជាមួយកម្មវិធី ISAF (ការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម) ដែលអនុវត្តដោយអង្គការអន្តរជាតិជាច្រើននៅកម្ពុជា។ |

| ថ្នាក់ក្រោមជាតិ | |
|---|---|
| | • ផ្តល់ការបណ្តុះបណ្តាលស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋ និងផ្តល់ប្រឹក្សាយោបល់ជាប្រចាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្តីពីការដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សា កិច្ចប្រជុំផ្សព្វផ្សាយ និងពិគ្រោះយោបល់ ការធ្វើសេចក្តីសម្រេច និងជំនាញសម្របសម្រួល។<br>• ធ្វើការសិក្សាអំពីយន្តការនៃការចូលរួមរបស់ប្រជាពលរដ្ឋនៅថ្នាក់ ក្រុង ស្រុក និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គការសង្គមស៊ីវិល ដើម្បីរៀបចំបញ្ជីអនុសាសន៍រួម សំដៅកែលម្អការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអនុវត្តអភិបាលកិច្ចមូលដ្ឋាន។<br>• ការសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងអង្គការសង្គមស៊ីវិល រដ្ឋបាលខេត្ត និងក្រុង ស្រុកគោលដៅនៅខេត្តបាត់ដំបង ។. តាមរយៈការតែងតាំងទីប្រឹក្សាអភិវឌ្ឍន៍របស់កម្មវិធី DAR នៅប្រចាំការជាមួយ រដ្ឋបាលខេត្តបាត់ដំបង។<br>• ការកសាងសមត្ថភាពរបស់អង្គការសង្គមស៊ីវិលនៅក្នុងខេត្តបាត់ដំបង ទាក់ទងនឹងការពង្រឹងបណ្តាញអង្គការសង្គមស៊ីវិល និងការតស៊ូមតិ។ |

# ប័ណ្ណព័ត៌មានៈ វិមជ្ឈការក្នុងវិស័យសុខាភិបាល

## ១. និន្នាការពន្ធនៅនៃការផ្តល់សេវាសុខាភិបាល

### ការផ្តល់សេវាសុខភាព (HSD)

មន្ទីរពេទ្យរដ្ឋ និងមណ្ឌលសុខភាព ផ្តល់សេវាសុខភាពបានប្រហែល ២០% នៃទីផ្សារសុខភាពក្នុងប្រទេសកម្ពុជាទាំងមូល។ ពួកគេផ្តោតជាសំខាន់លើអ្នកជំងឺ ដែលមានចំណូលទាប។ ទីផ្សារសុខភាព ៨០% ដែលនៅសេសសល់ ត្រូវបានបម្រើដោយវិស័យឯកជន តាមរយៈមន្ទីរពេទ្យឯកជន និងសប្បុរសធម៌ គ្លីនិក និងឱសថស្ថាន។ ប្រព័ន្ធផ្តល់សេវាសុខភាពរួមមាន មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលឯកទេសជាតិ សាកលវិទ្យាល័យ និងវិទ្យាស្ថានបណ្តុះបណ្តាលវិទ្យាសាស្ត្រសុខាភិបាល នៅរាជធានី ក្រោមការគ្រប់គ្រងផ្ទាល់របស់ក្រសួងសុខាភិបាល។ មន្ទីរពេទ្យបង្អែករាជធានី ខេត្ត (PRH) សរុបចំនួន ២៥ ដែលស្ថិតនៅក្នុងរាជធានី ខេត្តនីមួយៗ និងស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរសុខាភិបាលរាជធានី ខេត្ត (PHD)។ នៅថ្នាក់ស្រុក មានមន្ទីរពេទ្យបង្អែកស្រុក (DRH) ចំនួន ៩២ និងមណ្ឌលសុខភាពចំនួន ១.២២១ (HC) និងប៉ុស្តិ៍សុខភាពសហគមន៍ចំនួន ១២៧ នៅតាមសហគមន៍។ មណ្ឌលសុខភាព គឺជាកន្លែងទំនាក់ទំនងដំបូងរបស់អ្នកជំងឺ សម្រាប់សេវាថែទាំសុខភាពបឋម ហើយអ្នកជំងឺនឹងត្រូវបានបញ្ជូនទៅ "មន្ទីរពេទ្យបង្អែកខេត្ត ឬមន្ទីរពេទ្យបង្អែកស្រុក" (PRH, DRH) សម្រាប់សេវាបំពេញបន្ថែម ដែលត្រូវការការវះកាត់ ឬការសំរាកព្យាបាលនៅក្នុងមន្ទីរពេទ្យ។ អ្នកជំងឺត្រូវបញ្ជូនបន្តទៅមន្ទីរពេទ្យឯកទេសជាតិក្នុងរាជធានីភ្នំពេញ បើចាំបាច់។

នៅក្នុងគ្រឹះស្ថានសុខាភិបាលសាធារណៈ ធនធានហិរញ្ញវត្ថុ ឧបករណ៍ និងបុគ្គលិកនៅមានកម្រិតនៅឡើយ។ នេះជាមូលហេតុដែលនាំឱ្យគុណភាពនៃការផ្តល់សេវាសុខភាពសាធារណៈនៅមានកម្រិត និងមានការជឿទុកចិត្តតិចតួចពីសហគមន៍។ គេសង្កេតឃើញមានការកើនឡើងខ្លាំងនូវ "ការធ្វើការងារពីរកន្លែងរបស់បុគ្គលិកថែទាំសុខភាពសាធារណៈ" (បុគ្គលិកពេទ្យរដ្ឋទទួលយកការបំពេញការងារខាងក្រៅ បន្ថែមលើការងាររដ្ឋរបស់ខ្លួនបច្ចុប្បន្ន) ដែលទាក់ទាញអ្នកជំងឺទៅប្រើវិស័យឯកជនៈ វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា ឬឆ្មប ដែលធ្វើការនៅក្នុងស្ថាប័នសុខភាពសាធារណៈ ក៏ធ្វើការឱ្យស្ថាប័នផ្តល់សេវាសុខភាពឯកជនផងដែរ ដើម្បីបង្កើនប្រាក់ចំណូលរបស់ពួកគេ។

### រចនាសម្ព័ន្ធគ្រប់គ្រងសុខាភិបាល

**ថ្នាក់ជាតិៈ** ក្រសួងសុខាភិបាល
**ថ្នាក់ខេត្តៈ** រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំឡើងឱ្យមានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត(PHD)នៅតាមខេត្តនីមួយៗ។ មន្ទីរពេទ្យបង្អែកខេត្ត (PRH) ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត (PHD)។
**ថ្នាក់ស្រុកៈ** រួមមានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ (OD) ចំនួន ១០៣ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត (PHD)។ ជាទូទៅ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ (OD)មួយគ្របដណ្តប់ពី ២ ទៅ ៤ រដ្ឋបាលស្រុក (AD)។ មន្ទីរពេទ្យបង្អែកស្រុក មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព បច្ចុប្បន្នស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ (OD)។
**ថ្នាក់ឃុំៈ** នៅកម្រិតទាបបំផុត គឺគណៈកម្មាធិការគ្រប់គ្រងមណ្ឌលសុខភាព (ដឹកនាំដោយមេឃុំ ដើម្បីត្រួតពិនិត្យការអនុវត្ត និងការគ្រប់គ្រងរបស់មណ្ឌលសុខភាព)។ ក្រុមគាំទ្រសុខភាពភូមិ គាំទ្រសកម្មភាពលើកកម្ពស់សុខភាព និងបញ្ជូនមតិត្រឡប់ពីសហគមន៍ទៅកាន់មណ្ឌលសុខភាព។

## ប្រព័ន្ធសុខាភិបាលមុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាល




## ២. សមិទ្ធផលនៃវិមជ្ឈការក្នុងវិស័យសុខាភិបាល

នៅក្នុង "ការងារកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ" ដែលសម្របសម្រួលដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ លិខិតបទដ្ឋានគតិយុត្តសំខាន់ៗជាច្រើនត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនៅចុងឆ្នាំ២០១៩ និងដើមឆ្នាំ២០២០៖

- អនុក្រឹត្យលេខ ១៩៣ ស្តីពី "ការប្រគល់មុខងារគ្រប់គ្រងសុខភាព និងការផ្តល់សេវាសុខភាព ដល់រដ្ឋបាលរាជធានី ខេត្ត" បានផ្លាស់ប្តូរការគ្រប់គ្រងរបស់មន្ទីរសុខាភិបាល ពីក្រសួងសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ។
- ប្រកាសអន្តរក្រសួងនានាទាក់ទងនឹងការផ្ទេរបុគ្គលិក មុខងារ មូលនិធិ លក្ខខណ្ឌបច្ចេកទេស គណនេយ្យ និងសិទ្ធិអំណាចនៃហត្ថលេខាទៅឱ្យរដ្ឋបាលរាជធានី និងខេត្ត ។

ក្នុងឆ្នាំ២០២០ ផងដែរ បុគ្គលិកពេទ្យសរុបជាង ២០,១២៤នាក់ រួមមានវេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា និងឆ្មបជាដើម ត្រូវបានផ្ទេរពីក្រសួងសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី និងរដ្ឋបាលខេត្ត រួមជាមួយនឹងការទទួលខុសត្រូវថវិកាប្រចាំឆ្នាំ ចំនួន១៧០លានដុល្លា សម្រាប់ការចំណាយប្រតិបត្តិការ (ដាចម្បងសម្រាប់ប្រាក់ខែ)។ ថវិកាពីមុនដែលបានផ្ទេរពីក្រសួងសុខាភិបាលទៅឱ្យមន្ទីរសុខាភិបាលរាជធានី ខេត្ត ឥឡូវនេះត្រូវបានផ្ទេរពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទៅឱ្យរដ្ឋបាលរាជធានី ខេត្តសម្រាប់មន្ទីរសុខាភិបាល។ ក្រសួងសុខាភិបាល បន្តត្រួតពិនិត្យគុណភាពនៃការថែទាំ បង្កើតស្តង់ដារជាតិ និងទទួលខុសត្រូវ លើការបណ្តុះបណ្តាល និងការងារលទ្ធកម្ម ចំណែករដ្ឋបាលរាជធានី ខេត្តទទួលខុសត្រូវក្នុងការអនុវត្ត។ នៅក្នុងការអនុវត្តតួនាទីទាំងមូលរបស់ក្រសួង សុខាភិបាល នៅតែរឹងមាំ ទោះបីជាមានការផ្ទេរមុខងារទៅឱ្យរដ្ឋបាលរាជធានី ខេត្តហើយក៏ដោយ។ ម៉្យាងវិញទៀត រដ្ឋបាលរាជធានី ខេត្ត នៅតែស្វែងរកការបំពេញតួនាទីថ្មីៗបន្ថែមទៀត ដែលទាមទារភាពចាស់ទុំនៃការសម្របសម្រួល និងបណ្តាញទំនាក់ទំនង ចំណេះដឹង និងសមត្ថភាពក្នុងការរៀបចំថ្មីនេះ។

## ៣. ទិដ្ឋភាពនាពេលបច្ចុប្បន្ន

### ការផ្ទេរទ្រព្យសម្បត្តិ

លិខិតបទដ្ឋានគតិយុត្តនានា ដែលណែនាំដល់ការផ្ទេរ និងការគ្រប់គ្រងទ្រព្យសម្បត្តិ ពោលគឺ អគារ យានជំនិះ បរិក្ខារ។ល។ កំពុងត្រូវបានរៀបចំសេចក្តីព្រាងរួមគ្នាដោយក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (លេខាធិការដ្ឋាន គ.ជ.អ.ប)។ លិខិតបទដ្ឋានគតិយុត្តទាំងនោះ ត្រូវបានគេរំពឹងថានឹងត្រូវបានអនុម័តក្នុងពេលឆាប់ៗនេះ។

### វិមជ្ឈការនៅរដ្ឋបាលថ្នាក់ស្រុក

បច្ចុប្បន្ននេះ រដ្ឋបាលស្រុក មិនមានតួនាទីសំខាន់ក្នុងការផ្តល់សេវាសុខភាពទេ ព្រោះការិយាល័យសុខាភិបាលស្រុកប្រតិបត្តិចំនួន ១០៣ មិនត្រូវបានតម្រឹម ឬបន្សីជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ទាំង២០៤ ទេ។ ដូច្នេះហើយ រចនាសម្ព័ន្ធរដ្ឋបាលនៃវិស័យសុខាភិបាលនៅកម្ពុជា នៅតែមានលក្ខណៈមិនប្រក្រតីដូចគ្រប់វិស័យផ្សេងទៀត និងដែលការងាររដ្ឋបាលជាទូទៅមានការបែងចែកទៅតាមរដ្ឋបាលជា ២០៤ ក្រុង ស្រុក និងខណ្ឌ។ ការតម្រឹម ឬបន្សី រវាងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ នឹងកាត់បន្ថយការចំណាយលើប្រតិបត្តិការ និងដាក់ការគ្រប់គ្រងតាមវិស័យទាំងអស់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យនយោបាយដោយក្រុមប្រឹក្សាជាប់ឆ្នោត ដោយសារការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ផ្ទុយពីរដ្ឋបាលក្រុង ស្រុក ខណ្ឌ មិនមានក្រុមប្រឹក្សាជាប់ឆ្នោតទេ។ ក្រសួងសុខាភិបាល ពេញចិត្តក្នុងការរក្សាការិយាល័យ សុខាភិបាលស្រុកប្រតិបត្តិ ដើម្បីធានាថាការផ្តល់សេវាសុខភាពនៅតែមានសហរណកម្ម ដោយអ្នកជំងឺងាយស្រួលផ្លាស់ប្តូររវាងមណ្ឌលសុខភាព និងរវាងកម្រិតផ្សេងគ្នានៃប្រព័ន្ធបញ្ជូន។ ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ត្រូវបានបង្កើតឡើងដោយយោងតាមចំនួនប្រជាជននៅក្នុងតំបន់គ្របដណ្តប់ ដែលអង្គការសុខភាពពិភពលោកបានណែនាំសម្រាប់ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព។ ទោះជាយ៉ាងណាក៏ដោយ ស្ថានភាពបានផ្លាស់ប្តូរចាប់តាំងពីកំណែទម្រង់ការថែទាំសុខភាពលើកដំបូងក្នុងឆ្នាំ១៩៩៥។

### វិមជ្ឈការ និង ជំងឺកូវីដ-១៩

ជំងឺកូវីដ-១៩ បានពង្រឹងក្រសួងសុខាភិបាលក្នុងនាមជាអ្នកផ្តល់សេវាសាធារណៈក្នុងគ្រាមានវិបត្តិ ប៉ុន្តែក៏បានបង្ហាញយ៉ាងច្បាស់ពីតួនាទីសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកិច្ចខិតខំប្រឹងប្រែងក្នុងការសម្របសម្រួលកណ្តាល។ រដ្ឋបាលក្រុង ស្រុក ខណ្ឌ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើយុទ្ធនាការផ្សព្វផ្សាយការយល់ដឹង ក្នុងការពង្រឹងបទប្បញ្ញត្តិជាតិនៃការគ្រប់គ្រងជំងឺកូវីដ-១៩ ក្នុងការស្រាវជ្រាវតាមដានរកទំនាក់ទំនងសម្រាប់ការធ្វើតេស្ត និងក្នុងការគ្រប់គ្រង និងត្រួតពិនិត្យមជ្ឈមណ្ឌលចត្តាឡីស័ក។ តួនាទីសំខាន់ ដែលរដ្ឋបាលមូលដ្ឋាន បានបំពេញ ជាញឹកញាប់ត្រូវបានគេមើលរំលង។

## ៤. ទស្សនវិស័យ៖ កម្មវិធីជាតិ១០ឆ្នាំ ដំណាក់កាលទី២ (កជទី២)

កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរយៈពេល ១០ឆ្នាំដែលត្រូវបានអនុម័តនាពេលថ្មីៗនេះ ដែលហៅកាត់ថាកជទី២ (២០២១-២០៣០) បានអំពាវនាវឱ្យមានការសិក្សាស៊ីជម្រៅ ដើម្បីស្នើជាជម្រើសក្នុងការធ្វើឱ្យមានការចុះសម្រុងគ្នាក្នុងវិស័យសុខាភិបាល ។. ជាមួយនឹងការសិក្សាលទ្ធភាពផ្ទេរមុខងារសុខាភិបាលសមស្របពី

រដ្ឋបាលរាជធានី ខេត្ត ទៅឱ្យរដ្ឋបាលស្រុក។ នៅក្នុងវិស័យផ្សេងទៀត កិច្ចការទាំងនេះត្រូវបានផ្ទេររួចមកហើយ ដោយលិខិតបទដ្ឋានគតិយុត្តបន្ថែមត្រូវបានអនុម័តក្នុងឆ្នាំ២០១៩កន្លងមក។ កជទី២ អំពាវនាវឱ្យមានការសិក្សាលើជម្រើសសម្រាប់ការបង្កើតការិយាល័យសុខាភិបាលស្រុក/ក្រុង ដើម្បីស្វែងរកការតម្រឹម ឬបន្សុីការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ ជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ហើយវាផ្តល់នូវលទ្ធភាពក្នុងការបង្កើតនូវ យន្តការផ្តល់មូលនិធិថ្មី និងរចនាសម្ព័ន្ធអង្គការលេខថ្មី ដូចជា ភាពជាដៃគូរវាងរដ្ឋ និងឯកជន (ភ.រ.ជ) អង្គការសង្គមស៊ីវិល និងសហគ្រាសសង្គមជាដើម។ ការណ៍នេះ បើកលទ្ធភាពឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើការណែនាំគំរូអង្គភាពប្រកបដោយភាពច្នៃប្រឌិត ឧ. បង្កើតសេវារថយន្តសង្គ្រោះរួមគ្នាទូទាំងខេត្ត ឬទាញទីផ្សារសុខភាពឯកជនឱ្យចូលក្នុងវិស័យសាធារណៈវិញ។

## ៥. ទស្សនវិស័យៈ កម្មវិធី ធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា (ISD) ដែលទទួលបានសហហិរញ្ញប្បទានពី BMZ និង SDC, ០៣/២២ ដល់ ១២/២០២៥

កម្មវិធីធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា (ISD) ផ្តោតការគាំទ្ររបស់ខ្លួនលើការអនុវត្ត កជទី២ ។ ISD ស្វែងរកការគាំទ្រជាពិសេសដល់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ក្នុងការធ្វើការសម្រេចចិត្តប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយទាក់ទងនឹងវិស័យសុខាភិបាលដែលជាវិស័យមួយក្នុងចំណោមវិស័យផ្សេងទៀត។ ធាតុចូលរបស់ ISD អាចរួមមានដូចជា ការសិក្សាលទ្ធភាពនៃការផ្ទេរមុខងារ ដោយធ្វើការវិភាគ និងបង្កើតជម្រើសលើមុខងារសុខាភិបាលដែលអាចផ្ទេរពីរដ្ឋបាលខេត្ត ទៅឱ្យរដ្ឋបាលថ្នាក់ទាបជាង ឬ បង្កើតជម្រើសសម្រាប់ការិយាល័យសុខភាពក្រុង/ស្រុក។ លើសពីនេះ ISD ត្រូវធ្វើការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប ក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តមុខងារសុខាភិបាល ដូចដែលបានកំណត់ក្នុង កជទី២។

## ៦. ការគាំទ្រ GIZ

### ការផ្សព្វផ្សាយ អនុក្រឹត្យលេខ១៩៣

GIZ បានគាំទ្រលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងមហាផ្ទៃ ក្នុងការផ្សព្វផ្សាយអនុក្រឹត្យលេខ១៩៣ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងការផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត ។ នៅកម្ពុជា ការផ្សព្វផ្សាយច្បាប់ថ្មីជាផ្លូវការ គឺជាជំហានដ៏សំខាន់មួយ ដោយមានតំណាងថ្នាក់ជាតិ ប្រកាស និងជូនដំណឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈព្រឹត្តិការណ៍ដែលមានលក្ខណៈផ្លូវការ និងលក្ខណៈជាសាលប្រជុំធំៗ។ ជាធម្មតា បទប្បញ្ញត្តថ្មីៗ មានប្រសិទ្ធិភាពពិតប្រាកដបន្ទាប់ពីកម្មវិធីផ្សព្វផ្សាយបែបនេះ។

### ចក្ខុវិស័យសម្រាប់ការអនុវត្តមុខងារសុខាភិបាល

GIZ បានផ្តួចផ្តើមឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីភាគីពាក់ព័ន្ធជាច្រើន ដែលតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងតំណាងថ្នាក់ជាតិនៃវិស័យសុខាភិបាល និងវិស័យពាក់ព័ន្ធនានា ដើម្បីបង្កើន និងរកឱ្យឃើញពីផលប៉ះពាល់នៃបទបញ្ញត្តិស្តីពីវិមជ្ឈការដែលបានដាក់ឱ្យអនុវត្ត។ ដំណើរការរៀបចំចក្ខុវិស័យទូទៅសម្រាប់ការអនុវត្តការផ្តល់សេវាសុខាភិបាលដោយផ្អែកលើអនុក្រឹត្យលេខ១៩៣ និង កជទី២ ត្រូវបានធ្វើឡើង ហើយលទ្ធផលនៃដំណើរការនេះត្រូវបានគេរំពឹងថានឹងត្រូវប្រើក្នុងការរៀបចំផែនការអនុវត្ត៥ឆ្នាំ សម្រាប់ កជទី២ ក៏ដូចជាសម្រាប់ការពិចារណាក្នុងការរៀបចំកំណែទម្រង់វិស័យសុខា

ភិបាល។ ដំណើរការរៀបចំចក្ខុវិស័យនេះក៏មានគោលបំណងបង្កើតយន្តការចូលរួមដែលរឹងមាំ ដើម្បីដោះស្រាយបញ្ហា/សំណួរ ដែលមិនទាន់បានដោះស្រាយ/ឆ្លើយតប ដូចជាកំណែទម្រង់វិស័យសុខាភិបាល ការស្តារឡើងវិញក្រោយ ស្ថានភាពនៃជំងឺកូវីដ-១៩ ជាដើម។

### ៧. កិច្ចសហប្រតិបត្តិការរវាងកម្មវិធី DAR និងគម្រោងគាំពារសុខភាពសង្គម (SHP)៖

កម្មវិធី DAR គម្រោង SHP និងបណ្តាញវិស័យសុខាភិបាល និងគាំពារសង្គម (GIZ Sector Networks Health and Social Protection) បានរួមគ្នាផ្តល់វគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងមុខងារសុខាភិបាល និងការគ្រប់គ្រងជំងឺកូវីដ-១៩ ជាមួយសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA) របស់ក្រសួងមហាផ្ទៃ ។ លើសពីនេះ GIZ បានគាំទ្រដល់អាជ្ញាធរមូលដ្ឋាននានាក្នុងខេត្តបាត់ដំបង ក្នុងការផ្សព្វផ្សាយការយល់ដឹងអំពីជំងឺកូវីដ-១៩ ដល់ប្រជាពលរដ្ឋចំនួន ១២.៥០០នាក់។ កម្មវិធីទាំងពីរនេះ និងបណ្តាញវិស័យសុខាភិបាល និងគាំពារសង្គម ក៏បានសហការគ្នាក្នុងការបង្កើនទំនុកចិត្តរបស់តួអង្គថ្នាក់ក្រោមជាតិសំខាន់ៗដូចជា នាយក PHD, PRH, DRH និង HC ដើម្បីអនុវត្តការកែលម្អការផ្តល់សេវា សុខភាព។ អ្នកពាក់ព័ន្ធទាំងនេះមានការលើកទឹកចិត្តខ្ពស់ ក្នុងការប្រើប្រាស់ការអនុវត្តកំណែទម្រង់នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (SNDD) ដើម្បី កែលម្អការផ្តល់សេវាសុខភាព ហើយកត្តានេះ គឺជាធនធានដ៏ល្អមួយ ដែលអ្នករៀបចំគោលនយោបាយនៅថ្នាក់ជាតិ ជាពិសេសក្រសួងសុខាភិបាល (MoH) អាចបន្តបណ្តុះទំនុកចិត្ត និងកម្លាំងចិត្តបន្ថែមទៀតបាន។ ទោះជាយ៉ាងនេះក្តី បច្ចុប្បន្ននេះក្រសួងសុខាភិបាល ស្ទើរតែមិនដឹងថាមានធនធានទាំងនេះនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយសារវិធីសាស្ត្រគ្រប់គ្រងតាមបែបមជ្ឈការជាប្រវត្តិសាស្ត្ររបស់ពួកគេ។ គំនិតផ្តួចផ្តើមនេះបានទទួលមូលនិធិសម្រាប់ការបង្កើតថ្មីរបស់បណ្តាញវិស័យសុខាភិបាល និងគាំពារសង្គម ក្នុងឆ្នាំ២០២០ ដែលជួយផលិតបាននូវសមិទ្ធផលជាក់ស្តែងមួយចំនួនដូចខាងក្រោម៖



[វិធីសាស្ត្រដែលប្រើដោយមន្ទីរសុខាភិបាលខេត្ត ដោយមានការគាំទ្រពី SHPP & DAR]




[ការកែលម្អគុណភាពផ្អែកលើសេចក្តីមេត្តា សម្រាប់ប្រព័ន្ធថែទាំសុខភាព - ការអភិវឌ្ឍប្រកបដោយសុខភាពល្អ]



[ឧទាហរណ៍នៃលទ្ធផលរំពឹងទុកនៅថ្នាក់ស្រុក]

## Abbreviations

| | |
|---|---|
| AD | Administrative District<br>នាយករដ្ឋបាល |
| BMZ | Bundesministerium für wirtschaftliche Zusammenarbeit (German Federal Ministry for Economic Cooperation and Development)<br>ក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហប្រតិបត្តិការនៃសហព័ន្ធអាល្លឺម៉ង់ |
| C&PA | Capital and Provincial Administration<br>រដ្ឋបាលរាជធានី ខេត្ត |
| DRH | District Referral Hospital<br>មន្ទីរពេទ្យបង្អែកស្រុក |
| HC | Health Center<br>មណ្ឌលសុខភាព |
| HSD | Health Service Delivery<br>ការផ្តល់សេវាសុខភាព |
| ISD | Improved Service Delivery for Citizens in Cambodia<br>ធ្វើឱ្យប្រសើរឡើងដល់ការផ្តល់សេវាជូនប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា |
| MoH | Ministry of Health<br>ក្រសួងសុខាភិបាល |
| NASLA | National School for Local Administration<br>សាលាជាតិរដ្ឋបាលមូលដ្ឋាន |
| OD | Operational District<br>ការិយាល័យសុខាភិបាលស្រុក |
| PHD | Provincial Health Department<br>មន្ទីរសុខាភិបាលរាជធានី ខេត្ត |
| PRH | Provincial Referral Hospital<br>មន្ទីរពេទ្យបង្អែករាជធានី ខេត្ត |
| SHP | Social Health Protection, a GIZ Project<br>គាំពារសុខភាពសង្គម (គម្រោងរបស់ GIZ) |
| SNDD | Subnational Democratic Development Reform<br>ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |

# បណ្ណព័ត៌មាន៖ ការផ្ទេរមុខងារវិស័យអប់រំ

## ១) តើអ្វីទៅជាការផ្ទេរមុខងារក្នុងវិស័យអប់រំ ?

ការផ្ទេរមុខងារ គឺសំដៅទៅលើការបែងចែកការទទួលខុសត្រូវ និងធនធានពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ មុខងារនៃវិស័យអប់រំ ត្រូវបានផ្ទេរពីក្រសួងអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលខណ្ឌ/ស្រុក/ក្រុង (ថ្នាក់ក្រោមជាតិ) ដោយជឿជាក់ថាការផ្តល់សេវាអប់រំនឹងមានភាពប្រសើរឡើង បញ្ហានានានឹងត្រូវបានដោះស្រាយប្រកបដោយប្រសិទ្ធភាព ហើយប្រជាពលរដ្ឋនៅតាមមូលដ្ឋាននឹងទទួលបានអត្ថប្រយោជន៍ច្រើនជាងគេ។

## ២) មុខងារបានធ្វើប្រតិភូកម្ម ធៀបទៅនឹង មុខងារបានប្រគល់ក្នុងវិស័យអប់រំ៖

ការផ្ទេរមុខងារត្រូវបានធ្វើឡើងជាពីរបែប គឺការផ្ទេរតាមបែបនៃការប្រគល់ និងការផ្ទេរតាមបែបនៃការធ្វើប្រតិភូកម្ម។ នៅក្នុងការផ្ទេរតាមបែបនៃការប្រគល់ ដែលត្រូវបានគេយល់ថាជាទម្រង់បញ្ជូន (devolution) នៃវិមជ្ឈការ រដ្ឋបាលថ្នាក់ក្រោមជាតិដែលមានការឆ្លើយតប និងការទទួលខុសត្រូវ ត្រូវបានផ្តល់សិទ្ធិអំណាចជាអតិបរមាក្នុងការរៀបចំផែនការ គ្រប់គ្រង និងអនុវត្តមុខងារ។ ដោយឡែក ការផ្ទេរតាមបែបនៃការធ្វើប្រតិភូកម្ម មានន័យថារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពចំពោះក្រសួង ឬស្ថាប័នដែលបានប្រតិភូកម្មមុខងារឱ្យ។ ភាពខុសគ្នាជាចម្បងរវាងបែបផែននៃការផ្ទេរទាំងពីរនេះ គឺស្ថិតនៅលើកម្រិតនៃស្វ័យភាពរបស់ស្រុក និងក្រុង ក្នុងការបំពេញភារកិច្ច និងការទទួលខុសត្រូវនៅក្នុងមុខងារដែលបានផ្ទេរ។

## ៣) ការផ្ទេរមុខងារវិស័យអប់រំនៅកម្ពុជា៖

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានជ្រើសរើសវិធីសាស្ត្រពីរយ៉ាងក្នុងការផ្ទេរមុខងារវិស័យអប់រំ៖ មួយសម្រាប់ខេត្តបាត់ដំបង និងទីពីរសម្រាប់ខេត្ត និងរាជធានីដែលនៅសល់។

### ក) មុខងារអប់រំដែលបានធ្វើប្រតិភូកម្មក្រៅពីខេត្តបាត់ដំបង

មុខងារវិស័យអប់រំខាងក្រោមគឺត្រូវបានធ្វើប្រតិភូកម្មទៅដល់រដ្ឋបាល ខណ្ឌ ស្រុក ក្រុង ទាំងឡាយនៅក្នុងប្រទេសកម្ពុជាលើកលែងខេត្តបាត់ដំបង (សូមមើលក្នុងកថាខណ្ឌបន្ទាប់)

ក ការគ្រប់គ្រងអប់រំកុមារតូច
ខ ការគ្រប់គ្រងអប់រំបឋមសិក្សា
គ ការគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
ឃ ការងាររដ្ឋបាលគាំទ្រមធ្យមសិក្សាចំណេះទូទៅ
ង ការអភិវឌ្ឍយុវជន
ច ការអប់រំកាយ និងកីឡា

## ខ) មុខងារអប់រំដែលបានធ្វើប្រតិភូកម្ម និងបានប្រគល់ នៅខេត្តបាត់ដំបង

ក្រុង ស្រុកនៃខេត្តបាត់ដំបង កំពុងស្ថិតក្នុងដំណើរការសាកល្បង ដើម្បីអនុវត្តគោលនយោបាយវិមជ្ឈការក្នុងវិស័យអប់រំ ដែលមុខងារអប់រំទាំងនោះ ត្រូវបានផ្ទេរមិនត្រឹមតែតាមទម្រង់នៃការធ្វើប្រតិភូកម្មប៉ុណ្ណោះទេ ប៉ុន្តែតាមទម្រង់នៃការប្រគល់ផងដែរ ។

- <u>មុខងារបានធ្វើប្រតិភូកម្ម៖</u>

  ក. ការងាររដ្ឋបាលគាំទ្រមធ្យមសិក្សាចំណេះទូទៅ

  ខ. ការអភិវឌ្ឍយុវជន

  គ. ការអប់រំកាយ និងកីឡា

- <u>មុខងារបានប្រគល់៖</u>

  ក. ការគ្រប់គ្រងអប់រំកុមារតូច

  ខ. ការគ្រប់គ្រងអប់រំបឋមសិក្សា

  គ. ការគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ

## ៤) ឧទាហរណ៍សម្រាប់ភាពខុសគ្នានៃការផ្ទេរ៖

ក្រោមមុខងារដែលបានប្រគល់ “ការគ្រប់គ្រងការអប់រំបឋមសិក្សា” អភិបាលក្រុង ស្រុកក្នុងខេត្តបាត់ដំបងអាចធ្វើការតែងតាំងនាយកសាលាបឋមសិក្សាដោយផ្ទាល់ ដោយឡែកស្ថិតនៅក្រោមមុខងារដែលបានធ្វើប្រតិភូកម្ម អភិបាលក្រុង ស្រុកផ្សេងដទៃទៀត អាចសំណូមពរ ឬស្នើសុំបេក្ខភាពទៅក្រសួងអប់រំ យុវជន និងកីឡាតែប៉ុណ្ណោះតាមរយៈមន្ទីរអប់រំខេត្ត។ អនុវត្តដូចគ្នាចំពោះសិទ្ធិអំណាចក្នុងការផ្តល់ជូន ឬ បដិសេធសម្រាប់ការឈប់សម្រាក ការចេញលិខិតសរសើរ ឬចាត់វិធានការវិន័យ។ អនុក្រឹត្យលេខ ១៨២ ១៨៣ និង១៨៤ អនក្រ.បក គូសបញ្ជាក់ពីភារកិច្ច និងទំនួលខុសត្រូវលម្អិត ដែលរដ្ឋបាលក្រុង ស្រុក ត្រូវអនុវត្តក្នុងមុខងារដែលបានប្រគល់ និងមុខងារដែលបានធ្វើប្រតិភូកម្ម។

## ៥) ការគាំទ្ររបស់កម្មវិធី DAR ដែលអនុវត្តដោយ GIZ៖

កម្មវិធី DAR គាំទ្រដល់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគាំទ្រដល់ក្រសួងអប់រំ យុវជន និងកីឡា ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការផ្តល់គោលនយោបាយ និងប្រឹក្សាយោបល់បច្ចេកទេសសម្រាប់ការអនុវត្តមុខងារផ្ទេរក្នុងវិស័យអប់រំតាំងពីកម្មវិធី EU-SPACE 2 (2013-2015) និង EU DAR (2016-2019) មកម្ល៉េះ។

## សមិទ្ធផលសំខាន់ៗនៃវិមជ្ឈការក្នុងវិស័យអប់រំ

- អនុក្រឹត្យលេខ១៨២, ១៨៣ និង១៨៤ ចេញក្នុងឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ខណ្ឌ ស្រុក ដែលបានធ្វើសមាហរណកម្មការិយាល័យអប់រំ យុវជន និងកីឡា (ដែលពីមុននៅក្រោមសមត្ថកិច្ចរបស់ក្រសួង/មន្ទីរអប់រំ យុវជន និងកីឡា) ទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក។ ក្នុងអនុក្រឹត្យនេះក៏មានរាយបញ្ជីមុខងារអប់រំដែលបានធ្វើប្រតិភូកម្ម និងមុខងារដែលបានប្រគល់ផងដែរ។
- នៅឆ្នាំ២០២០ និងឆ្នាំ២០២១ សំណុំនៃបទប្បញ្ញត្ត សេចក្តីសម្រេច ប្រកាសអន្តរក្រសួង (បទប្បញ្ញត្តប្រតិបត្តិនៅកម្រិតក្រសួង) ស្តីពីបុគ្គលិក និងការបែងចែកធនធានហិរញ្ញវត្ថុ និងលក្ខខណ្ឌបច្ចេកទេស និងនីតិវិធីនៃការប្រើប្រាស់ថវិកាដែលបានបែងចែកដើម្បីអនុវត្តមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធត្រូវបានដាក់ចេញ។ បុគ្គលិកអប់រំប្រហែល១៩៥នាក់ (នាយករង/នាយកបុគ្គលិកការិយាល័យអប់រំ បុគ្គលិករដ្ឋបាល និងហិរញ្ញវត្ថុ) និងគ្រូបង្រៀន ៦.៥១៩នាក់ នៃមត្តេយ្យសិក្សា និងបឋមសិក្សា រួមជាមួយនឹងទឹកប្រាក់ចំនួន ៣៣.៦លានដុល្លារសហរដ្ឋអាមេរិក(ឆ្នាំសារពើភ័ណ្ឌ ២០២១) សម្រាប់ប្រាក់ខែគ្រូ និងសម្រាប់ការអនុវត្តមុខងារការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធ និងប្រហែលជា ៧៦៣.៤២៥ដុល្លារសហរដ្ឋអាមេរិក (ឆ្នាំសារពើភ័ណ្ឌ២០២១) សម្រាប់ប្រាក់ខែបុគ្គលិក និងសម្រាប់ចំណាយប្រតិបត្តិការនៃការិយាល័យអប់រំដែលបានផ្ទេរពីក្រសួង/មន្ទីរអប់រំ យុវជន និងកីឡា ទៅរដ្ឋបាលក្រុង ស្រុក ក្នុងខេត្តបាត់ដំបង។
- ក្រុមប្រឹក្សាស្រុកបាណន់ និងស្រុកថ្មគោលនៃខេត្តបាត់ដំបង បានបង្កើតគណៈកម្មាធិការមួយដែលមានគោលបំណងពង្រឹងវិជ្ជាជីវៈរបស់ក្រុមប្រឹក្សាក្នុងការបំពេញនូវភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការគ្រប់គ្រងមុខងារវិស័យអប់រំដែលបានផ្ទេរទៅដល់ពួកគាត់។ ដោយឡែករដ្ឋបាលក្រុង ស្រុកដទៃទៀត ក៏កំពុងតែពិនិត្យ និងអនុវត្តតាមផងដែរ។ ការបង្កើតគណៈកម្មាធិការនេះឡើង គឺមានសារៈសំខាន់ណាស់សម្រាប់ដំណើរការវិមជ្ឈការក្នុងគោលដៅពីរ គឺដើម្បីលើកកម្ពស់ការផ្តល់សេវាមួយផ្នែក និងមួយផ្នែកទៀតគឺដើម្បីបង្ហាញថា រដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាដែលជាប់ឆ្នោត បានប្រើប្រាស់នូវអណត្តិទូទៅរបស់ខ្លួនដើម្បីគ្រប់គ្រង និងផ្តល់សេវាអប់រំដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

## ការអភិវឌ្ឍន៍នានាក្នុងពេលបច្ចុប្បន្ន៖

- ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប បាននឹងកំពុងរៀបចំនូវសេចក្តីព្រាងឯកសារគតិយុត្តដើម្បីផ្ទេរការគ្រប់គ្រងទ្រព្យសម្បត្តិវិស័យអប់រំ ដូចជា ដីសាលារៀន អាគារ យានយន្តសម្ភារការិយាល័យដល់រដ្ឋបាលក្រុង ស្រុក។ កិច្ចពិភាក្សារវាងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យសម្រេចលើឯកសារគតិយុត្តទាំងនោះត្រូវបានរំពឹងទុកថានឹងត្រូវបញ្ចប់ក្នុងរយៈពេលប៉ុន្មានខែខាងមុខនេះ។

- ឯកសារបច្ចេកទេស និងឯកសារបណ្តុះបណ្តាល ស្តីពីអនុវត្តមុខងារវិស័យអប់រំ កំពុងត្រូវបានរៀបចំដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងពាក់ព័ន្ធ។ ឯកសារទាំងនេះ សង្ឃឹមថានឹងត្រូវបានសម្រេច និងប្រគល់ឱ្យរដ្ឋបាលក្រុង ស្រុក ក្នុងឆ្នាំ២០២២។
- មន្ទីរអប់រំ យុវជន និងកីឡាក្នុងខេត្តបាត់ដំបង កំពុងជួយដល់រដ្ឋបាលក្រុង ស្រុក ដើម្បីធានាបានការផ្ទេរមុខងារក្នុងវិស័យអប់រំដោយរលូន ជាពិសេស ពីព្រោះមេរៀនទទួលបានពីខេត្តបាត់ដំបងនឹងត្រូវបានចងក្រងជាឯកសារសម្រាប់ប្រើប្រាស់ក្នុងការតម្រង់ទិសឆ្ពោះទៅកាន់ខេត្តដទៃទៀត នៃប្រទេសកម្ពុជានាពេលខាងមុខ។

## អក្សរកាត់

| | |
|---|---|
| DAR | កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាលសាធារណៈ |
| EU-DAR | កម្មវិធីសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាលសាធារណៈ |
| EU-SPACE | កម្មវិធីសហភាពអឺរ៉ុប ដើម្បីការលើកកម្ពស់ការបំពេញការងារគណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ |

# ប័ណ្ណព័ត៌មាន៖ អំពីការិយាល័យច្រកចេញចូលតែមួយ

## ១. តើការិយាល័យច្រកចេញចូលតែមួយ គឺជាអ្វី?



*ប្រជាពលរដ្ឋមកដាក់ពាក្យស្នើសុំសេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយក្នុងស្រុកបាណន់ ខេត្តបាត់ដំបង (រូបភាព៖ © GIZ/លោក មិន សារ៉ាំង)*

ការិយាល័យច្រកចេញចូលតែមួយ(OWSO) គឺជាទីតាំងផ្តល់សេវារដ្ឋបាលនៅកន្លែងតែមួយ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ពោលគឺនៅរដ្ឋបាលស្រុក ក្រុង ខណ្ឌ ដែលជាកន្លែងផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋ និង អាជីវកម្មខ្នាតតូច។ ការិយាល័យច្រកចេញចូលតែមួយនីមួយៗ មានផ្នែកជួរមុខ និងផ្នែកជួរក្រោយ។ ផ្នែកជួរមុខ មានមន្ត្រី ដែលធ្វើទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ប្រគល់ទម្រង់បែបបទ និងទទួលឯកសារ ចំណែកផ្នែកជួរក្រោយ មាន 'មន្ត្រីជំនាញ' ដែលពីមុនត្រូវបានធ្វើប្រតិភូកម្មពីក្រសួងស្ថាប័នជំនាញ ឱ្យមកបំពេញការងារ នៅការិយាល័យច្រកចេញចូលតែមួយ ។ បច្ចុប្បន្នការិយាល័យជំនាញនៃក្រសួងស្ថាប័នទាំងនោះ ត្រូវបានដាក់បញ្ចូលទៅក្នុងរចនាសម្ព័ន្ធ និងការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ នៅថ្នាក់រាជធានី ខេត្ត ស្ថាប័ននេះមានឈ្មោះថា អង្គភាពច្រកចេញចូលតែមួយ (OWSU) ដែលមានរចនាសម្ព័ន្ធដូចគ្នានឹងការិយាល័យច្រកចេញចូលតែមួយដែរ ដោយមានផ្នែកជួរមុខ និងផ្នែកជួរក្រោយ។ សេវារដ្ឋបាលដែលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយ និងអង្គភាពច្រកចេញចូលតែមួយ មានភាពខុសគ្នាទាក់ទងនឹងវិសាលភាព និង/ឬទំហំ ឧទាហរណ៍ដូចជា ការអនុញ្ញាតឱ្យសាងសង់ផ្ទះទំហំតិចជាង ៥០០ម៉ែត្រការ៉េ គឺជាសមត្ថកិច្ចរបស់ការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំពោះអគារដែលមានទំហំលើសពី ៥០០ម៉ែត្រការ៉េ ស្ថិតនៅក្រោមសមត្ថកិច្ចរបស់អង្គភាពច្រកចេញចូលតែមួយនៅរដ្ឋបាលរាជធានី ខេត្ត។

ការបង្កើតការិយាល័យច្រកចេញចូលតែមួយ មានគោលបំណងលើកកម្ពស់គុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការិយាល័យច្រកចេញចូលតែមួយ ផ្តល់សេវារដ្ឋបាលកាន់តែខិតជិតដល់ប្រជាពលរដ្ឋ សម្របសម្រួលការឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេបានទាន់ពេលវេលា និងកាត់បន្ថយអំពើពុករលួយ។ តម្លៃសេវា និងរយៈពេលផ្តល់សេវាជាមធ្យម ត្រូវបានដាក់បង្ហាញជាសាធារណៈ ដើម្បីបង្កើនតម្លាភាពសម្រាប់ អតិថិជន។ នៅតាមការិយាល័យប្រជាពលរដ្ឋដែលស្ថិតនៅជាមួយការិយាល័យច្រកចេញចូលតែមួយ ប្រជាពលរដ្ឋអាចដាក់បណ្តឹងតវ៉ាដោយអនាមិក អំពីការមិនពេញចិត្តចំពោះសេវារដ្ឋបាល (សូមមើលព័ត៌មានអំពីការិយាល័យប្រជាពលរដ្ឋ)។ ម្ចាស់អាជីវកម្មខ្នាតតូច កន្លែងជួសជុល ភោជនីយដ្ឋាន ឬ ផ្ទះសំណាក់ ទទួលបានអត្ថប្រយោជន៍ពីការិយាល័យច្រកចេញចូលតែមួយជាពិសេស ដោយមូលហេតុថាពួកគេអាចចុះបញ្ជីអាជីវកម្មបានយ៉ាងឆាប់រហ័ស និងដោយរលូននៅតាមការិយាល័យច្រកចេញចូលតែមួយដែលបំពេញការងារបានពេញលេញ។

## ២. ទិន្នន័យ និងស្ថានភាពជាក់ស្តែង

"ការិយាល័យច្រកចេញចូលតែមួយ" ចំនួនពីរដំបូងគេ ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងដោយក្រសួងមហាផ្ទៃ ចន្លោះឆ្នាំ២០០៤ និង២០០៧ នៅរដ្ឋបាលក្រុងបាត់ដំបង និងក្រុងសៀមរាប ក្រោមគម្រោង Konrad-Adenauer-

giz

Foundation/EU AsiaUrb ។ ក្រោយមក ការិយាល័យច្រកចេញចូលតែមួយ ត្រូវបានបង្កើតឡើងនៅក្នុងក្រុងចំនួន២៤ ខណ្ឌចំនួន០៨ និងស្រុកចំនួន០២ ក្នុងក្របខ័ណ្ឌនៃគម្រោងសហហិរញ្ញប្បទានរបស់ធនាគារពិភពលោក(WB) ជាមួយរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅចន្លោះឆ្នាំ២០០៩ និង ២០១៤។ ក្នុងឆ្នាំ២០១៩ មានការិយាល័យច្រកចេញចូលតែមួយសរុបចំនួន១១៥ រួមមាន រដ្ឋបាលក្រុងចំនួន២៧ រដ្ឋបាលខណ្ឌចំនួន១៤ និង រដ្ឋបាលស្រុកចំនួន៧៤ បានដំណើរការ។ ដោយសារបញ្ហាហិរញ្ញវត្ថុ និង/ឬធនធានមនុស្ស យន្តការច្រកចេញចូលតែមួយ(OWSM) ត្រូវបានបង្កើតឡើង ជំនួសឱ្យការិយាល័យច្រកចេញចូលតែមួយ ដែលមានស្តង់ដារពេញលេញនៅក្នុងរដ្ឋបាលស្រុកចំនួន៨៨ ទៀតដែលនៅសេសសល់។ ភាពខុសគ្នារវាងការិយាល័យច្រកចេញចូលតែមួយ និងយន្តការច្រកចេញចូលតែមួយ គឺថា ការិយាល័យច្រកចេញចូលតែមួយ មានអគារស្តង់ដារមួយដែលមានការបែងចែកច្បាស់លាស់ 'ផ្នែកជួរមុខ' និង 'ផ្នែកជួរក្រោយ' ដែលមានការិយាល័យជំនាញតាមវិស័យ មានសម្ភារៈ បរិក្ខារពេញលេញនៅក្រោមដំបូលតែមួយ។ ចំណែកយន្តការច្រកចេញចូលតែមួយ មានត្រឹមតែ 'ផ្នែកជួរមុខ' ប៉ុណ្ណោះ។ បុគ្គលិកមកពីការិយាល័យជំនាញផ្សេងៗ នៅតែធ្វើការនៅតាមការិយាល័យជំនាញរៀងៗខ្លួន ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុក។



*អគារថ្មីនៃការិយាល័យច្រកចេញចូលតែមួយរបស់ស្រុករុក្ខគិរី ខេត្តបាត់ដំបង (រូបភាព៖ © GIZ/លោក មិន សារ៉ាំង)*

នៅខែធ្នូ ឆ្នាំ២០១៩ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៨២ ១៨៣ និង១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ អនុក្រឹត្យនេះតម្រូវឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ រៀបចំរចនាសម្ព័ន្ធឡើងវិញដោយ (ក)បង្កើតការិយាល័យថ្មីជាច្រើន ដូចជាការិយាល័យច្រកចេញចូលតែមួយ ឬ ការិយាល័យលេខាធិការក្រុមប្រឹក្សា និង (ខ) ធ្វើសមាហរណកម្មការិយាល័យថ្នាក់ស្រុកនៃក្រសួងស្ថាប័នជំនាញទាំងអស់ លើកលែងតែវិស័យសុខាភិបាល ឱ្យស្ថិតនៅក្រោមរចនាសម្ព័ន្ធតែមួយរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ នេះមានន័យថា ការិយាល័យច្រកចេញចូលតែមួយ ត្រូវតែស្ថិតនៅក្រោមរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ដូច្នេះការិយាល័យច្រកចេញចូលតែមួយទាំងអស់ កំពុងត្រូវបានផ្លាស់ប្តូរទៅជាការិយាល័យច្រកចេញចូលតែមួយដែលមានស្តង់ដារតែមួយ។ គិតត្រឹមខែមករា ឆ្នាំ២០២១ មានការិយាល័យច្រកចេញចូលតែមួយសរុបទាំងអស់ចំនួន២០៤ ក្នុងនោះចំនួន២៨នៅរដ្ឋបាលក្រុង ចំនួន១៤នៅរដ្ឋបាលខណ្ឌ ចំនួន១៦២នៅរដ្ឋបាលស្រុក។ ដោយផ្អែកលើអនុក្រឹត្យទាំងបីខាងលើ មុខងារចំនួន៥៥ បន្ថែមទៀត រួមទាំងមុខងារផ្តល់សេវារដ្ឋបាលថ្មី[1] នៅក្នុងវិស័យចំនួន២០ ក៏ត្រូវបានផ្ទេរទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌផងដែរ។ សេវារដ្ឋបាលមួយចំនួនកំពុងត្រូវបានផ្តល់ជូនប្រជាពលរដ្ឋ ក្រោយពេលដែលលិខិតបទដ្ឋានគតិយុត្តគាំទ្រការអនុវត្ត ដូចជាសៀវភៅណែនាំបច្ចេកទេស ត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

បច្ចុប្បន្ន ការិយាល័យច្រកចេញចូលតែមួយ ផ្តល់សេវារដ្ឋបាលជាង៣០០សេវា ក្នុងវិស័យចំនួន១៤។ ក្នុងចំណោមសេវារដ្ឋបាលទាំងនោះ ការងារនីត្យានុកូលកម្មសៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ ឬវិញ្ញាបនបត្រសិស្ស ជាសេវាដែលប្រជាពលរដ្ឋស្នើសុំច្រើនជាងគេនៅគ្រប់ក្រុង ស្រុក ក្នុងខេត្តបាត់ដំបង។ ដោយសារជំងឺរាតត្បាតកូវីដ-១៩ ការិយាល័យច្រកចេញចូលតែមួយស្រុកបវេល បានផ្តួចផ្តើមផ្តល់សេវាអនឡាញ ដោយប្រើទំព័រហ្វេសបុក (Facebook) របស់ពួកគេ។

[1] ឱ. សេវារដ្ឋបាលសម្រាប់វិស័យឧស្សាហកម្ម និងសិប្បកម្ម ១. ការគ្រប់គ្រង និងការចុះញ្ជីសិប្បកម្ម សហគ្រាសធនតូចដែលគ្មានហានិភ័យ ២. សេវាកម្មបើកកន្លែងជួសជុលគ្រឿងអគ្គិសនី អេឡិចត្រូនិច លាងរថយន្ត និងលាងម៉ូតូ

ប្រជាពលរដ្ឋ អាចស្នើសុំធ្វើនីត្យានុកូលកម្មលើឯកសាររបស់ពួកគេតាមប្រព័ន្ធអនឡាញ (online) ហើយមកទទួលឯកសារដែលធ្វើនីត្យានុកូលកម្មរួចនៅពេលឯកសារទាំងនោះរួចរាល់។

ក្នុងចំណោមការិយាល័យច្រកចេញចូលតែមួយទាំង១៤ ក្នុងខេត្តបាត់ដំបង មានការិយាល័យច្រកចេញចូលតែមួយចំនួន៨ បានចាប់ផ្តើមផ្តល់សេវាអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ដោយសហការជាមួយមន្ត្រីនគរបាលមូលដ្ឋាន។ តាមរយៈលទ្ធផលរកឃើញពីការសិក្សាប្រៀបធៀបរបស់ជី អាយ ហ្សេត (GIZ) ក្នុងខែសីហា ឆ្នាំ២០១៧ និងខែកក្កដា ឆ្នាំ២០១៨ នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង បានបង្ហាញថា ប្រជាពលរដ្ឋមានការពេញចិត្តចំពោះការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ ហើយចំណេះដឹងរបស់ពួកគេអំពីការិយាល័យច្រកចេញចូលតែមួយបានកើនឡើងពី ២៥% ទៅ ៩៧%។

## ៣. ការគាំទ្ររបស់ជីអាយហ្សេត

ជី អាយ ហ្សេត បានចាប់ផ្តើមចូលរួមជាមួយនាយកដ្ឋានមុខងារ និងធនធាន នៃក្រសួងមហាផ្ទៃ ក្នុងកិច្ចការងារទាក់ទងនឹងការិយាល័យច្រកចេញចូលតែមួយ ក្នុងឆ្នាំ២០១៣ ហើយបានបង្កើនកិច្ចសហប្រតិបត្តិការនេះក្នុងអំឡុងពេលអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិមជ្ឈការ និងរដ្ឋបាល (DAR) ដែលផ្តល់ហិរញ្ញប្បទានដោយក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហប្រតិបត្តិការនៃសហព័ន្ធអាល្លឺម៉ង់ (BMZ)។ ជី អាយ ហ្សេត គាំទ្រដល់ក្រសួងមហាផ្ទៃ ផ្តោតលើប្រធានបទការិយាល័យច្រកចេញចូលតែមួយ ទាំងក្នុងការរៀបចំគោលនយោបាយនៅថ្នាក់ជាតិ និងការអនុវត្តនៅថ្នាក់ក្រោមជាតិ។

កន្លងមក ជី អាយ ហ្សេត បានធ្វើការជាមួយក្រសួងមហាផ្ទៃក្នុងការបង្កើតអនុសាសន៍ស្តីពីជម្រើស និងគោលការណ៍ណែនាំសម្រាប់ការបង្កើតយន្តការច្រកចេញចូលតែមួយនៅរដ្ឋាភិបាលថ្នាក់ក្រោមជាតិ។ ដោយមានកិច្ចសហការជាមួយនាយកដ្ឋានមុខងារ និងធនធាន លទ្ធភាពសម្រាប់ការពង្រីកការិយាល័យច្រកចេញចូលតែមួយនៅក្នុងរដ្ឋបាលក្រុង ស្រុកបន្ថែមទៀត ត្រូវបានសិក្សា ក្នុងគោលបំណងបង្កើតការិយាល័យច្រកចេញចូលតែមួយជាដំហានៗ នៅតាមរដ្ឋបាលក្រុង ស្រុក នៅទូទាំងប្រទេសកម្ពុជា។ ការិយាល័យច្រកចេញចូលតែមួយ ចំនួន២៩ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៨ និងចំនួន៣១ នៅឆ្នាំ២០១៩។

នៅថ្នាក់ក្រោមជាតិ បុគ្គលិកដែលបម្រើការងារនៅការិយាល័យច្រកចេញចូលតែមួយ ត្រូវបានគាំទ្រតាមរយៈការកសាងសមត្ថភាព ការផ្តល់ប្រឹក្សាយោបល់ និងការបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ច និងនីតិវិធីការងារ ដោយផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសដល់បុគ្គលិកផ្នែកជួរក្រោយ និងការរៀបចំកម្មវិធីសិក្សាចែករំលែកបទពិសោធន៍រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងរវាងថ្នាក់ក្រោមជាតិ តាមរយៈការចងក្រងឯកសារបទពិសោធន៍ល្អៗក្នុងការផ្តល់សេវា ឬ ការរៀបចំទស្សនកិច្ចក្នុងស្រុក។ លើសពីនេះ ស្រុកដៃគូក្នុងខេត្តកណ្តាល និងបាត់ដំបង ត្រូវបានគាំទ្រតាមរបៀបផ្សេងៗពាក់ព័ន្ធនឹងការលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋានអំពីការផ្តល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយ។

ថ្មីៗនេះ កម្មវិធី DAR បានធ្វើការជាមួយនាយកដ្ឋានមុខងារ និងធនធាន ក្រសួងមហាផ្ទៃ លើការកែសម្រួលប្រកាស និងសៀវភៅណែនាំស្តីពីគោលការណ៍ និងនីតិវិធីផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។ គ្រូបង្គោលថ្នាក់ជាតិ ត្រូវបានបណ្តុះបណ្តាល និងឯកសារសម្រាប់បណ្តុះបណ្តាលអំពីប្រកាស និងសៀវភៅណែនាំដែលបានកែសម្រួល ត្រូវបានរៀបចំឡើង។ ទន្ទឹមនឹងនេះ កម្មវិធី DAR ក៏បានធ្វើការជាមួយការិយាល័យច្រកចេញចូលតែមួយ ក្នុងខេត្តបាត់ដំបងក្នុងការរៀបចំរចនាសម្ព័ន្ធឡើងវិញដោយផ្អែកលើបទប្បញ្ញត្តិថ្មី។

ការសាកល្បងផ្ដល់សេវាតាមប្រព័ន្ធឌីជីថលកំពុងដំណើរការនៅក្នុងស្រុកមោងឫស្សី និងស្រុកបវេល ខេត្តបាត់ដំបង ហើយថ្នាលឌីជីថលកំពុងត្រូវបានរៀបចំឡើង ដើម្បីជួយគ្រប់គ្រង និងត្រួតពិនិត្យការផ្ដល់សេវារដ្ឋបាលនៅការិយាល័យច្រកចេញចូលតែមួយ។ ប្រជាពលរដ្ឋអាចទទួលបានព័ត៌មានអំពីសេវារដ្ឋបាល និងអាចតាមដានស្ថានភាពនៃពាក្យស្នើសុំសេវារដ្ឋបាលរបស់ពួកគេនៅការិយាល័យច្រកចេញចូលតែមួយ តាមរយៈកម្មវិធីទូរស័ព្ទ។ កម្មវិធីទូរស័ព្ទនេះនឹងជួយប្រជាពលរដ្ឋក្នុងការកាត់បន្ថយ និងសន្សំសំចៃពេលវេលាក្នុងការស្វែងរកព័ត៌មានអំពីសេវាដែលផ្ដល់ដោយការិយាល័យច្រកចេញចូលតែមួយ ក៏ដូចជាតាមដានស្ថានភាពនៃពាក្យស្នើសុំសេវារដ្ឋបាលរបស់ពួកគេ ដែលពេលខ្លះតម្រូវឱ្យធ្វើដំណើរទៅមកជាច្រើនដង ដោយគ្រាន់តែពិនិត្យមើល ឬសួរថាតើសេវារបស់ពួកគេរួចរាល់ហើយឬនៅ។ លើសពីនេះ វានឹងកាត់បន្ថយអំពើពុករលួយ និងធានាតម្លាភាពក្នុងការផ្ដល់សេវាជូនប្រជាពលរដ្ឋ។

## អក្សរកាត់

| | |
|---|---|
| CP | Capital and Provincial Administration<br>រដ្ឋបាលរាជធានី និងរដ្ឋបាលខេត្ត |
| DAR | Decentralisation and Administrative Reform Programme<br>កម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល |
| DMKAs | District/Municipal/Khan Administrations<br>រដ្ឋបាលស្រុក ក្រុង ខណ្ឌ |
| DFR | Department of Function and Resources<br>នាយកដ្ឋានមុខងារ និងធនធាន |
| MoI | Ministry of Interior<br>ក្រសួងមហាផ្ទៃ |
| OWSM | One Window Service Mechanism<br>យន្តការច្រកចេញចូលតែមួយ |
| OWSU | One Window Service Unit<br>អង្គភាពច្រកចេញចូលតែមួយ |
| OWSO | One Window Service Office<br>ការិយាល័យច្រកចេញចូលតែមួយ |
| RGC | Royal Government of Cambodia<br>រាជរដ្ឋាភិបាលកម្ពុជា |
| SNAs | Sub-National Administrations<br>រដ្ឋបាលថ្នាក់ក្រោមជាតិ |

# ប័ណ្ណព័ត៌មាន៖ មុខងារជាជម្រើសរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ

## ១. តើមុខងារជាជម្រើសជាអ្វី?

សមាជិក សមាជិកាក្រុមប្រឹក្សានៃថ្នាក់ក្រោមជាតិ (ឬ "ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន") - នៅថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ជួបប្រទះនូវបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនជារៀងរាល់ថ្ងៃ។ ក្នុងនាមជាអ្នកតំណាងដែលកើតឡើងដោយការបោះឆ្នោត សមាជិក សមាជិកាក្រុមប្រឹក្សាជាអ្នកដំបូងគេ ដែលប្រជាពលរដ្ឋមករក ដើម្បីស្នើសុំជួយដោះស្រាយបញ្ហា/ក្តីកង្វល់ និងតម្រូវការរបស់ខ្លួន។

កន្លងមក រដ្ឋបាលថ្នាក់មូលដ្ឋាន និងក្រុមប្រឹក្សា បានឆ្លើយតបទៅនឹងសំណើរបស់ប្រជាពលរដ្ឋ ជាញឹកញាប់ថា៖ «សូមទោស! យើងមិនអាចជួយលោក អ្នកបានទេ ពីព្រោះយើងមិនមានសមត្ថកិច្ចលើបញ្ហានេះទេ» ឬ «សូមទោស! យើងមិនទទួលខុសត្រូវលើបញ្ហានេះទេ»។ ការណ៍នេះគឺច្រើនតែទុកឱ្យប្រជាពលរដ្ឋដោះស្រាយបញ្ហារបស់ពួកគេដោយខ្លួនឯង។

ការអនុវត្តគោលនយោបាយវិមជ្ឈការនៅក្នុងប្រទេសកម្ពុជាបានធ្វើឱ្យមានការផ្លាស់ប្តូរសេណារីយ៉ូនេះ។ ក្រុមប្រឹក្សាដែលកើតពីការបោះឆ្នោតទាំងអស់នៅថ្នាក់ក្រោមជាតិមាន**មុខងារជាអាណត្តិទូទៅ** (ឬ «**មុខងារជាជម្រើស**») ក្នុងការដោះស្រាយបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋ។ នេះមានន័យថា សមាជិក សមាជិកានៃក្រុមប្រឹក្សាទាំងអស់នៅគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិមានទំនួលខុសត្រូវក្នុងការស្តាប់ និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ការបំពេញទំនួលខុសត្រូវនោះ ជាញឹកញយ វាមិនមែនជាកិច្ចការ ដែលងាយស្រួលក្នុងការអនុវត្តនោះទេ។ សំណួរផ្សេងៗអាចកើតឡើងដូចជា៖ «តើយើង ដែលជាក្រុមប្រឹក្សា អាចធ្វើអ្វីមួយបានទេ ដើម្បីដោះស្រាយបញ្ហាដោយសហការជាមួយរដ្ឋបាលនិងការិយាល័យជំនាញ? ឬក៏ តើមានច្បាប់ លិខិតបទដ្ឋានគតិយុត្ត កម្មវិធី និងដំណោះស្រាយសម្រាប់បញ្ហានេះនៅថ្នាក់លើ (ដូចជាថ្នាក់ខេត្ត ឬក្រសួងនៅថ្នាក់ជាតិ) ដែលយើងត្រូវអនុវត្តតាម ដើម្បីដោះស្រាយបញ្ហានៅកម្រិតរបស់យើងដែរឬទេ?"

មុខងារ ដែលបានកំណត់ដោយច្បាប់រៀបចំអង្គការឆ្នាំ២០០៨[1] គឺជាអំពើ ឬសកម្មភាពដែលរួមមានការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងទៀត។ មុខងារជាជម្រើស (ដែលមិនមែនជាមុខងារជាកាតព្វកិច្ច) សំដៅលើមុខងារទាំងឡាយណា ដែលត្រូវបានជ្រើសរើសយកមកអនុវត្តដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងដើម្បីជាផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ មុខងារជាជម្រើស រួមមាន៖

- មុខងារទាំងឡាយណា ដែលមិនស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន ឬអង្គភាពណាមួយរបស់រដ្ឋាភិបាល និង
- មុខងារទាំងឡាយណា ដែលស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន អង្គភាពរបស់រដ្ឋាភិបាល ប៉ុន្តែក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធទាំងនោះ មិនមានការជំទាស់នឹងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការជ្រើសរើស និងអនុវត្តមុខងារទាំងនោះឡើយ។

[1] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុម័តឆ្នាំ២០០៨

**<u>ការកំណត់ន័យនៃមុខងារជាអាណត្តិទូទៅ (មុខងារជាជម្រើស) នៅក្នុងការអនុវត្តជាក់ស្តែង៖</u>**

គ្រប់សកម្មភាព ឬការសម្រេចចិត្តរបស់ក្រុមប្រឹក្សា ឬរបស់រដ្ឋបាលមូលដ្ឋាន មិនអាចត្រូវបានចាត់ទុកថាជាការអនុវត្តមុខងារជាអាណត្តិទូទៅនោះទេ។ ឧទាហរណ៍ សមាជិក ឬសមាជិកាក្រុមប្រឹក្សាម្នាក់ ដែលប្រមូលប្រាក់ដើម្បីយកទៅឧបត្ថម្ភដល់គ្រួសារក្រីក្រសម្រាប់ឱ្យពួកគេយកទៅចំណាយលើថ្លៃសេវាសុខភាព ឬថ្លៃសេវាដឹកអ្នកជម្ងឺទៅមន្ទីរពេទ្យ ជាអំពើដ៏ល្អណាស់។ ក៏ប៉ុន្តែ សកម្មភាពបែបនេះ***មិន***ស្ថិតក្រោមអត្ថន័យនៃសកម្មភាព ដែលស្ថិតក្រោមមុខងារជាអាណត្តិទូទៅរបស់ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិទេ ដូច្នេះហើយ វាមិនត្រូវបានចាត់ទុកថាជាមុខងារជម្រើសឡើយ។ ***សកម្មភាពបែបនេះ ស្ថិតនៅក្នុងមុខងារជាអណត្តិទូទៅបាន លុះត្រាតែក្រុមប្រឹក្សាបានផ្តួចផ្តើមជាផ្លូវការ និងធ្វើការសម្រេចចិត្តជាផ្លូវការនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ដើម្បីអនុវត្តគម្រោង ឬសកម្មភាពនេះ ឬ ប្រសិនបើក្រុមប្រឹក្សាធ្វើការសម្រេចចិត្តគ្រប់គ្រងស្ថានភាពនេះតាមរយៈការដាក់ចេញដីកាដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋពាក់ព័ន្ធ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ក្នុងន័យនេះ ដំណើរការ និងការសម្រេចចិត្តទាំងនេះ ត្រូវបានចាត់ទុកថាជាការអនុវត្តមុខងារជាអាណត្តិទូទៅ ដោយក្រុមប្រឹក្សាហើយ។***

ចរិតលក្ខណៈនៃគម្រោង និងសកម្មភាព ដែលត្រូវបានអនុវត្តក្រោមមុខងារជាអាណត្តិទូទៅរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចមានភាពខុសគ្នាខ្លាំង៖

- គម្រោង ឬសកម្មភាព អាចជាការសម្រេចចិត្តដែលមានលក្ខណៈសាមញ្ញមួយលើក ជាបទបញ្ជា ឬជាសកម្មភាពរបស់រដ្ឋបាលមូលដ្ឋាន (ជួនកាលវាមានទម្រង់ជាដីកា) ដើម្បីដោះស្រាយបញ្ហាមួយ។
- គម្រោង ឬសកម្មភាពអាចជាសេវា ដែលបង្កើតឡើងសម្រាប់ពេលវេលាកំណត់ណាមួយ ឬគ្មានដែនកំណត់ ដើម្បីដោះស្រាយបញ្ហា ឬតម្រូវការរបស់ប្រជាជននៅមូលដ្ឋាន។
- គម្រោង ឬសកម្មភាពអាចជាសកម្មភាពនានា ដែលមិនត្រូវការចំណាយថវិកា ឬចំណាយថវិកាតិចតួច ឬចំណាយថវិកាច្រើន ដរាបណាគម្រោង ឬសកម្មភាពនោះផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ច។
- គម្រោង ឬសកម្មភាពអាចផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ ការវិនិយោគ ឬសេវាកម្មសង្គម។

***លិខិតបទដ្ឋានគតិយុត្តដ៏សំខាន់ ដែលពិពណ៌នា និងកំណត់និយមន័យ មុខងារជាអាណត្តិទូទៅ របស់ក្រុមប្រឹក្សាមូលដ្ឋាន គឺ "អនុក្រឹត្យស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយរដ្ឋបាលថ្នាក់ក្រោមជាតិ"។*** *ក៏ប៉ុន្តែនៅមាន****បទប្បញ្ញត្តិសំខាន់ៗមួយចំនួនទៀតផងដែរ ដែលមាននៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*** *និងនៅក្នុង****ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*** *បទប្បញ្ញត្តិទាំងនេះបញ្ជាក់យ៉ាងច្បាស់ថា* ***"ក្រុមប្រឹក្សាត្រូវគ្រប់គ្រង និងអនុវត្តមុខងារជាជម្រើសក្នុងកម្រិតអតិបរមាដែលអាចធ្វើទៅបាន"*** *ហើយថា* ***"ក្រុមប្រឹក្សាត្រូវគ្រប់គ្រង និងប្រើប្រាស់ថវិកា ដែលរួមទាំងការចំណាយដើម្បីអនុវត្តមុខងារជាជម្រើសប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងរដ្ឋាភិបាល"។***

មុខងារជាជម្រើស ត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ការទទួលខុសត្រូវរបស់អ្នកតំណាងជាប់ឆ្នោតក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន និងលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគណនេយ្យភាព តម្លាភាព ប្រសិទ្ធភាព និងសមធម៌ ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ផ្អែកលើគោលបំណងខាងលើ និងអនុវត្តតាមគោលបំណង ដែលថា ***រដ្ឋាភិបាលមូលដ្ឋានផ្តល់សេវាកាន់តែប្រសើរដល់ប្រជាពលរដ្ឋ*** កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិមជ្ឈការ និងរដ្ឋបាល (DAR) របស់ GIZ គាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាដៃគូក្នុងការអនុវត្តមុខងារជាជម្រើស។ម្យ៉ាងវិញទៀត កម្មវិធីនេះចង់ឱ្យក្រុមប្រឹក្សាដៃគូធ្វើការផ្តួចផ្តើមគំនិតរបស់ខ្លួន និងអនុវត្តមុខងារនានាដែលបានជ្រើសរើសដោយខ្លួនឯង ដើម្បីជាប្រយោជន៍ដល់ប្រជាពលរដ្ឋ។

## ២. ស្ថានភាពជាក់ស្តែង និង តួលេខពិត

ច្បាប់រៀបចំអង្គការឆ្នាំ២០០៨ បានកំណត់មុខងារសំខាន់ពីសម្រាប់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។ ក្រៅពីការអនុវត្តមុខងារជាកាតព្វកិច្ច ក្រុមប្រឹក្សា ត្រូវបានលើកទឹកចិត្តឱ្យផ្តួចផ្តើម និងអនុវត្តមុខងារជាជម្រើស ជាពិសេស មុខងារដែលទាក់ទងនឹងសេវាសង្គម។ លិខិតបទដ្ឋានគតិយុត្តដែលបានដាក់ចេញជាបន្តបន្ទាប់ ដូចជា អនុក្រឹត្យលេខ២៨៥ អនក្រ បក ស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើស និងអនុក្រឹត្យលេខ៣៦ អនក្រ បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក បានជួយក្រុមប្រឹក្សាក្នុងការផ្តួចផ្តើមគំនិត និងអនុវត្តមុខងារនេះ។ លេខាធិការដ្ឋាន គ.ជ.អ.ប បានបោះពុម្ពឯកសារបច្ចេកទេសស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារជាជម្រើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យដំណើរការអនុវត្តរបស់ក្រុមប្រឹក្សាមានភាពរលូន។




*រូបទី ១៖ ឯកសារបច្ចេកទេសស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងអនុវត្តមុខងារជាជម្រើស*

## ៣. ការគាំទ្ររបស់កម្មវិធី DAR

GIZ បានគាំទ្រក្រុមប្រឹក្សា និងរដ្ឋបាលក្នុងការអនុវត្តមុខងារជាជម្រើស នៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល ហៅថា គម្រោង EU-DAR ដែលផ្តល់ហិរញ្ញប្បទានដោយសហភាពអឺរ៉ុប។ គម្រោងនេះបានដំណើរការពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩។ GIZ បាននិងកំពុងបង្កើនកិច្ចសហប្រតិបត្តិការ និងការខិតខំប្រឹងប្រែងនេះក្នុងអំឡុងពេលអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល បច្ចុប្បន្ន ហៅថា កម្មវិធី DAR ដែលអនុវត្តពីខែឧសភា ឆ្នាំ២០១៩ ដល់ខែមេសា ឆ្នាំ២០២២។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃលទ្ធផលសំខាន់ៗដែលទាក់ទងនឹងការអនុវត្តមុខងារជាជម្រើស៖

- ក្រុមប្រឹក្សាដៃគូ និងបុគ្គលិកក្រុមប្រឹក្សាទទួលបាននូវការបណ្តុះបណ្តាល និងការប្រឹក្សាយោបល់ពីទីប្រឹក្សាអភិបាលកិច្ចមូលដ្ឋាន (LGAs) របស់ GIZ ដើម្បីឱ្យពួកគាត់ប្រើប្រាស់វិធីសាស្ត្រមួយ ហៅថា **ការសម្របសម្រួលក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា**។ នេះជាវិធីសាស្ត្រដែលផ្តោតលើដំណើរការក្នុងគោលបំណងពង្រឹងសមត្ថភាពក្រុមប្រឹក្សាក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើព័ត៌មានគ្រប់ជ្រុងជ្រោយ។ វិធីសាស្ត្រនេះដើរតួនាទីជាផែនទីបង្ហាញផ្លូវ ដើម្បីចង្អុលបង្ហាញក្រុមប្រឹក្សា និងបុគ្គលិករបស់ក្រុមប្រឹក្សា ក្នុងការដោះស្រាយបញ្ហានានា ដែលពួកគាត់បានទទួល។ វិធីសាស្ត្រចែកចេញជាច្រើនដំហាន ដោយរាប់ចាប់ពី ការកំណត់និងការ

ចាត់អាទិភាពបញ្ហា ការធ្វើការសម្រេចចិត្ត ការបង្កើតដំណោះស្រាយចំពោះបញ្ហាដោយមានការចូលរួម ការជ្រើសរើសយកជម្រើសសមស្រប និងការអនុវត្តសកម្មភាពដែលឆ្លើយតបទៅនឹងជម្រើសដែលបានជ្រើសរើស។

- ចាប់ពីខែឧសភា ឆ្នាំ២០១៦ ដល់ខែវិច្ឆិកា ឆ្នាំ២០២១ មានសេវាចំនួន៥៤ ដែលស្ថិតនៅក្នុងវិស័យផ្សេងៗត្រូវបានផ្តល់ដោយក្រុមប្រឹក្សា និងរដ្ឋបាលដៃគូនៅក្នុងខេត្តបាត់ដំបង និងខេត្តកណ្តាល ដោយប្រើវិធីសាស្ត្រ**សម្របសម្រួលក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សា**។ GIZ ជាញឹកញាប់ បានគាំទ្រដំណើរការនេះជាមួយនឹងការផ្តល់មូលនិធិខ្នាតតូច ដោយមានគោលដៅបង្កើនជំនាញគ្រប់គ្រងហិរញ្ញវត្ថុ និងគ្រប់គ្រងគម្រោងរបស់សមាជិក សមាជិកាក្រុមប្រឹក្សា។
- GIZ បានលើកកម្ពស់ឱ្យមានការផ្លាស់ប្តូរបទពិសោធន៍ និងការរៀនសូត្រតាមខ្សែទទឹងរវាងរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលក្រុង ស្រុក ក៏ដូចជាតាមខ្សែបណ្តោយរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័ននៅថ្នាក់ជាតិ។ ការផ្លាស់ប្តូរបទពិសោធន៍ និងការរៀនសូត្រទ្រង់ទ្រាយធំចំនួន៥លើក ត្រូវបានរៀបចំក្នុងគោលបំណងលើកទឹកចិត្តដល់រដ្ឋបាលក្រុង ស្រុក ដែលមិនមែនជាដៃគូរបស់គម្រោង EU-DAR ឱ្យមានការផ្តួចផ្តើម និងឆ្លើយតបប្រកបដោយប្រសិទ្ធភាព ចំពោះតម្រូវការដែលស្នើឡើង ដោយប្រជាពលរដ្ឋ។ ការផ្លាស់ប្តូរបទពិសោធន៍និងការរៀនសូត្រ ក៏ត្រូវបានផ្តួចផ្តើមដោយដៃគូក្នុងខេត្តបាត់ដំបងផងដែរ ឧទាហរណ៍ សិក្ខាសាលាចែករំលែកបទពិសោធន៍ស្តីពីសណ្តាប់ធ្នាប់ទីផ្សារ ដំណើរការសាលាបឋមសិក្សា និងមត្តេយ្យសិក្សា ការប្រើប្រាស់គ្រឿងញៀន ឬការគ្រប់គ្រងសំរាម កាកសំណល់រឹង។



*រូបទី ២៖ សិស្សានុសិស្សលាងសម្អាតដៃជាក្រុម ស្រុកគាស់ក្រឡ (រូបថត៖ © GIZ/ Miguel Jerónimo)*

- ដើម្បីលើកកម្ពស់សិទ្ធិអំណាចបញ្ញត្តិរបស់ក្រុមប្រឹក្សាក្នុងការរៀបចំដាក់ចេញដីកា ដែលមានលក្ខណៈជាបទបញ្ជាទូទៅ GIZ ផ្តល់ការអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិកក្រុមប្រឹក្សាអំពីការរៀបចំដាក់ចេញដីកាមួយចំនួន ដូចជា ដីកាអំពីការគ្រប់គ្រងសំរាម សំណល់រឹង (រួមទាំងកម្រៃសេវាប្រមូលសំរាម) និងដីកាអំពីការលើកកម្ពស់សុខុមាលភាពកុមារ និងការលក់ដូរចំណីអាហារនៅតាមសាលាបឋមសិក្សានៅក្នុងស្រុកដៃគូចំនួន៤ ដែលជាផ្នែកសំខាន់នៃការអនុវត្តមុខងារជាជម្រើសរបស់ខ្លួន។
- ការពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (WCCC) គឺប្រធានបទសំខាន់មួយនៃការងាររបស់ GIZ ដោយសារគណៈកម្មាធិការនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកសំណើ និងផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាអំពីតម្រូវការរបស់ស្ត្រី កុមារ និងក្រុមងាយរងគ្រោះ។ គណៈកម្មាធិការ WCCC គឺជាបណ្តាញស្នូលដើម្បីរាយការណ៍អំពីបញ្ហាសង្គមជូនទៅរដ្ឋបាល និងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។
- អត្ថបទចំនួន១៤ ត្រូវបានផ្សព្វផ្សាយនៅលើទំព័រប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ក្រុង ស្រុកដៃគូ ពោលគឺនៅលើ FACEBOOK ដើម្បីជូនដំណឹងដល់ប្រជាពលរដ្ឋអំពីការវិនិយោគសាធារណៈ និងអំពីសកម្មភាពនានាទាក់ទងនឹងសំណើរបស់ប្រជាពលរដ្ឋ (គណនេយ្យភាព)។

## ឧបសម្ព័ន្ធ៖ បញ្ជីគំរូនៃមុខងារជាជម្រើស (សិក្សាចងក្រងដោយលោកបណ្ឌិត PETER KÖPPINGER និងលោក ឈិន ទេពភិរម្យ ក្នុងក្របខ័ណ្ឌនៃគម្រោង EU DAR ឆ្នាំ២០១៨)

បញ្ជីគម្រោង ឬសកម្មភាពដែលបានអនុវត្តដោយរដ្ឋបាលក្រុង ស្រុក ដែលបានជ្រើសរើសក្នុងវិស័យផ្សេងៗគ្នា

### ក.សុខភាព

- គាំទ្រសាលាបឋមសិក្សាដើម្បីធានាថាសិស្សានុសិស្សអនុវត្តតាមស្តង់ដារអនាម័យដៃជាមូលដ្ឋាន និងអ្នកលក់ដូរចំណីអាហារនៅក្នុងបរិវេណសាលាប្រកាន់ខ្ជាប់តាមស្តង់ដារអនាម័យចំណីអាហារជាមូលដ្ឋាន
- ការផ្តល់ និងអប់រំអំពីអនាម័យសហគមន៍ និងទឹកស្អាត (រួមទាំងអណ្តូងខួង និងស្រះ)
- ផ្សព្វផ្សាយអំពីអនាម័យសហគមន៍ និងការយល់ដឹងអំពីសុខភាព ការលើកកម្ពស់សុខភាពមាតា
- ជួយដឹកជញ្ជូនស្ត្រីមានផ្ទៃពោះទៅកាន់មណ្ឌលសុខភាព

### ខ.ការអប់រំ

- ការរៀបចំ ការគាំទ្រ ការកែលម្អមត្តេយ្យសិក្សាសហគមន៍
- ការជួយឧបត្ថម្ភសិស្សានុសិស្សនៅតាមសាលាបឋមសិក្សា[2]
- ការសម្របសម្រួល និងការកៀរគរធនធានពីអង្គការក្រៅរដ្ឋាភិបាល ដើម្បីសាងសង់សាលាបឋមសិក្សា[2]

### គ.ជំនួយសង្គម និងសន្តិសុខសង្គម

- ការផ្តល់អាហារ និងទីជំម្រកសម្រាប់មនុស្សចាស់ជរា
- ការផ្តល់អាហារូបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះ មនុស្សចាស់ជរា និងកុមារមកពីគ្រួសារក្រីក្រ និងកុមារដែលគេបោះបង់ចោល
- ការកៀរគរធនធានដើម្បីគាំទ្រដល់មនុស្សចាស់ជរា ជនពិការ ស្ត្រីមេម៉ាយក្រីក្រ កុមារកំព្រាក្នុងសហគមន៍ ប្រជាពលរដ្ឋដែលរងគ្រោះដោយសារគ្រោះមហន្តរាយធម្មជាតិ
- ការដាក់ចេញដីកាស្តីពីសន្តិសុខសង្គម
- ការសម្របសម្រួលគាំទ្រអតីតយុទ្ធជន ដើម្បីពួកគេទទួលបានដីធ្លីសម្រាប់សាងសង់លំនៅដ្ឋាន

### ឃ.បរិស្ថាន

- ការគ្រប់គ្រងសំរាម សំណល់រឹង (រួមទាំង ការដាក់ចេញដីកា)
- ការរៀបចំទីលានចាក់សំរាម ដោយសហការជាមួយអ្នកម៉ៅការឯកជន
- ការសម្របសម្រួលជាមួយកសិដ្ឋានចិញ្ចឹមជ្រូកដើម្បីបញ្ឈប់ការបង្ហូរទឹកស្អុយទៅក្នុងស្រែ និងបឹង ទន្លេ
- ការហាមប្រាមការបង្ហូរកាកសំណល់មានសារជាតុពុលចេញពីរោងចក្រចូលទៅក្នុងស្ទឹង ទន្លេ
- ការដាក់ចេញដីកាសម្រាប់ការគ្រប់គ្រងការពារ និងការអភិរក្សតំបន់ព្រៃឈើ

[2] មុខងារ ដែលត្រូវបានផ្ទេរ នៅចុងឆ្នាំ២០១៩

## ខ. ការការពារសិទ្ធិ និងច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈ

- ផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងសម្រាប់ការការពារ និងផ្តល់ការគាំទ្រប្រឆាំងនឹងអំពើហឹង្សាក្នុងគ្រួសារ
- ជួយរៀបចំសណ្តាប់ធ្នាប់សាធារណៈនៅក្នុងសាលាបឋមសិក្សា និងផ្សារ រួមទាំងបញ្ហាចំណតរថយន្ត
- ធានាសណ្តាប់ធ្នាប់សាធារណៈនៅតាមដងផ្លូវ និងផ្សារ
- ការសម្របសម្រួលចរាចរណ៍ផ្លូវគោកឱ្យមានសណ្តាប់ធ្នាប់
- ការដោះស្រាយវិវាទដីធ្លី បន្ទាប់ពីមានបណ្តឹងនៅរដ្ឋបាលមូលដ្ឋានដោយមានការចូលរួមពីព្រះសង្ឃ និងសមាជិកក្រុមប្រឹក្សា
- ការសម្រុះសម្រួលក្នុងវិវាទកើតឡើងរវាងនិយោជក និងកម្មករ បន្ទាប់ពីមានការតវ៉ានៅរដ្ឋបាលមូលដ្ឋាន

## ច. ការអភិវឌ្ឍសេដ្ឋកិច្ច

- ការផ្តួចផ្តើមបង្កើតសមាគមកសិកម្មនៅតាមសហគមន៍ ឬវិធានការបង្កើនតម្លៃផលិតផលកសិកម្ម
- ការរៀបចំគោលដៅទេសចរណ៍ធម្មជាតិ
- ការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពដល់កសិករអំពីការចិញ្ចឹមសត្វ និងការថែសួនសរីរាង្គ/ផលិតកម្មកសិកម្ម
- ការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រីអំពីជំនាញកាត់ដេរ ហាងកែសម្ផស្ស ការចិញ្ចឹមត្រី និងការថែសួនតាមផ្ទះ
- ការសហការជាមួយក្រុមហ៊ុនបៃតងសម្រាប់ការនាំចេញអង្ករ

## ឆ. ហេដ្ឋារចនាសម្ព័ន្ធជនបទ

- ការសាងសង់ និងការស្តារផ្លូវជនបទ សាលាបឋមសិក្សា ប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹក ហេដ្ឋារចនាសម្ព័ន្ធសុខភាពសហគមន៍
- ការសម្របសម្រួលដើម្បីកែលម្អនូវលទ្ធភាពទទួលបានចរន្តអគ្គិសនីដើម្បីប្រើប្រាស់

## ជ. ការគ្រប់គ្រងគ្រោះមហន្តរាយ

- ការរៀបចំទីកន្លែងដែលមានសុវត្ថិភាពក្នុងកំឡុងពេលមានទឹកជំនន់ និងវិធានការផ្សេងៗទៀតដើម្បីដោះស្រាយករណីបន្ទាន់ និងគ្រោះមហន្តរាយ

## ញ. ផ្សេងៗ

- គាំទ្រការផ្សព្វផ្សាយចំណេះដឹងលើសេវារដ្ឋបាលផ្តល់ដោយការិយាល័យច្រកចេញចូលតែមួយ
- រៀបចំសួនច្បារ និងចាក់បេតុងក្នុងទីប្រជុំជន និងបរិវេណក្នុងសាលាស្រុក

# ប័ណ្ណព័ត៌មាន៖ ប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម

## ១. តើប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្មជាអ្វី?

ប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម (PMS) សំដៅលើដំណើរការ និងនីតិវិធីនៃការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក និងអ្នកគ្រប់គ្រងរបស់អង្គភាព ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព ក៏ដូចជាសមត្ថភាពផ្នែករដ្ឋបាល និងផលិតភាពការងាររបស់មន្ត្រីរាជការស៊ីវិល ដើម្បីឱ្យពួកគេអាចសម្រេចបាននូវគោលដៅ ដែលបានកំណត់នៅក្នុងផែនការការងាររបស់ពួកគេ។

នៅក្នុងបរិបទប្រទេសកម្ពុជា ក្រសួងមុខងារសាធារណៈ គឺជាក្រសួងទទួលខុសត្រូវក្នុងការរៀបចំ ដឹកនាំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម ដែលប្រព័ន្ធនេះមានឧបករណ៍សម្រាប់អនុវត្តសំខាន់ៗ ដូចខាងក្រោម៖

ផែនការការងារប្រចាំឆ្នាំ ការពិពណ៌នាមុខតំណែង (Position Description-PD) លក្ខខណ្ឌការងារ ឬកិច្ចព្រមព្រៀងស្តីពីការបំពេញការងារ ការត្រួតពិនិត្យវត្តមាន លំហូររបាយការណ៍ និងអភិក្រមស្តង់ដារក្នុងការត្រួតពិនិត្យ និងវាយតម្លៃផ្នែកលើសមិទ្ធកម្ម។ សមាសធាតុទាំងអស់នេះ ត្រូវបានរៀបចំឡើង ដោយរំពឹងទុកថាវានឹងបង្កើនសមត្ថភាពបំពេញការងាររបស់មន្ត្រីក្នុងវិស័យសាធារណៈឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ។




បច្ចុប្បន្ននេះ ឧបករណ៍ទាំងអស់របស់ប្រព័ន្ធគ្រប់គ្រងផ្នែកលើសមិទ្ធកម្ម មិនទាន់បានដាក់ឱ្យអនុវត្តទាំងស្រុងនោះទេ។ ឧទាហរណ៍ជាក់ស្តែង ឧបករណ៍ពាក់ព័ន្ធនឹងការវាយតម្លៃផ្នែកលើសមិទ្ធកម្មមិនទាន់បានដាក់ឱ្យអនុវត្តទេ ដោយសារបញ្ហាថវិកាដែលត្រូវប្រើប្រាស់សម្រាប់ជារង្វាន់លើកទឹកចិត្តដល់មន្ត្រី ដែលកត្តានេះទាមទារឱ្យរាជរដ្ឋាភិបាលត្រូវធ្វើការវិភាជន៍ថវិកា

ជាតិ ដើម្បីប្រើសម្រាប់ផ្តល់ជាការលើកទឹកចិត្ត ការទទួលស្គាល់ និងជារង្វាន់ជូនដល់មន្ត្រីដែលមានស្នាដៃការងារឆ្នើម។ ក្នុងចំណោមឧបករណ៍ទាំងអស់នេះ ការពិពណ៌នាមុខតំណែង គឺជាឧបករណ៍មួយដែលត្រូវបានចាត់ទុកថាមានភាពជាប់ពាក់ព័ន្ធបំផុត ទៅនឹងការកែលម្អទៅលើសមិទ្ធកម្ម និងផលិតភាពរបស់មន្ត្រី ក្នុងរដ្ឋបាលសាធារណៈ។ នៅក្នុងខែមិថុនា ឆ្នាំ២០១៦ ការពិពណ៌នាមុខតំណែងនេះគឺជាឧបករណ៍ដំបូងគេបំផុត ដែលត្រូវបានណែនាំដោយក្រសួងមុខងារសាធារណៈ (MCS) ឱ្យអនុវត្តនៅតាមបណ្តាក្រសួង ស្ថាប័នថ្នាក់ជាតិទាំងអស់។

ការពិពណ៌នាមុខតំណែង សំដៅទៅលើការពិពណ៌នាបែបទូទៅនៃមុខតំណែងនីមួយៗ ដែលមាននៅក្រោមរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ឬអង្គភាព។ ឧទាហរណ៍ គណៈអភិបាល (BoG) នៃរដ្ឋបាលក្រុង ស្រុក(DMA) មានមុខតំណែងចំនួនពីរ ដែលមានមុខតំណែងជាអភិបាល និងអភិបាលរង ដែលនេះមានន័យថា ការពិពណ៌នាមុខតំណែងបែបទូទៅមានចំនួនពីរដែរ ដែលមួយគឺជាមុខតំណែងអភិបាល និងមួយទៀតជាមុខតំណែងអភិបាលរង។ ការពិពណ៌នាមុខតំណែងដែលមានលក្ខណៈទូទៅ ចាំបាច់ត្រូវធ្វើការកែសម្រួលទៅតាមបរិបទ និងតម្រូវការជាក់ស្តែងរបស់រដ្ឋបាលក្រុង ស្រុកនីមួយៗ ជាពិសេសត្រូវពិចារណាចំពោះមុខតំណែងអភិបាលរង ដែលអាចមានចំនួនដល់ទៅ ០៥មុខតំណែង។ ខ្លឹមសារដែលមាននៅក្នុងការពិពណ៌នាមុខតំណែងបែបទូទៅ រួមមានឈ្មោះមុខតំណែង តួនាទីនិងការទទួលខុសត្រូវ និងលក្ខណសម្បត្តិស័ក្តិសមសម្រាប់មុខតំណែងនីមួយៗ។ ក្រៅពីឆ្លុះបញ្ចាំងពីព្រំដែនកំណត់នៃតួនាទី ការទទួលខុសត្រូវ និងកិច្ចការដែលត្រូវបំពេញនៅក្នុងមុខតំណែងនីមួយៗ ការពិពណ៌នាមុខតំណែងក៏ត្រូវបានប្រើប្រាស់ ក្នុងគោលបំណងដើម្បីធ្វើការជ្រើសរើស តែងតាំង អភិវឌ្ឍអាជីព និងអភិវឌ្ឍសមត្ថភាពផងដែរ។ ដើម្បីបង្កភាពងាយស្រួលក្នុងការរៀបចំ និងប្រើប្រាស់ការពិពណ៌នាមុខតំណែងក្នុងលក្ខណៈស្តង់ដារតែមួយដូចគ្នាក្នុងរដ្ឋបាលសាធារណៈ ក្រសួងមុខងារសាធារណៈ បច្ចុប្បន្នកំពុងរៀបចំឯកសារណែនាំស្តីពីការរៀបចំការពិពណ៌នាមុខតំណែង ក្នុងគោលបំណងណែនាំដល់បណ្តាក្រសួង ស្ថាប័ននៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) អំពីរបៀបក្នុងការរៀបចំ និងកែសម្រួលការពិពណ៌នាមុខតំណែងបែបទូទៅ សម្រាប់គ្រប់មុខតំណែងដែលមាននៅក្រោមរចនាសម្ព័ន្ធរបស់ខ្លួន។

## ២. ស្ថានភាពជាក់ស្តែង និង តួលេខពិត

រហូតមកដល់ពេលនេះ មានក្រសួង ស្ថាប័នចំនួន១១ ក្នុងចំណោមក្រសួង ស្ថាប័នចំនួន២៨ ដែលបានរៀបចំការពិពណ៌នាមុខតំណែងរួចរាល់ សម្រាប់បុគ្គលិករបស់ខ្លួននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាមួយគ្នានេះ ក្រសួងមុខងារសាធារណៈ លេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD-S) និងក្រសួងមហាផ្ទៃ (MoI) កំពុងរៀបចំការពិពណ៌នាមុខតំណែងសម្រាប់មុខតំណែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទើបត្រូវបានធ្វើសមាហរណកម្មថ្មីៗចូលទៅក្នុង រចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ស្របតាមអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក កាលពីខែធ្នូ ឆ្នាំ២០១៩។

បច្ចុប្បន្នការពិពណ៌នាមុខតំណែងបែបទូទៅសម្រាប់មុខតំណែងចំនួន៣ នៅតាមការិយាល័យនីមួយៗក្នុងចំណោមការិយាល័យទាំង១៣ របស់រដ្ឋបាលក្រុង ស្រុក និងមុខតំណែងគ្រប់គ្រងចំនួន៤ កំពុងត្រូវបានរៀបចំ ដោយសារមានការផ្លាស់ប្តូររចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុកឱ្យស្របតាមគោលការណ៍នៃរដ្ឋបាលឯកភាព[1]៖

| ល.រ | ឈ្មោះការិយាល័យ/កម្រិតមុខតំណែងគ្រប់គ្រង | ចំនួន ការពិពណ៌នាមុខតំណែងបែបទូទៅ |
|---|---|---|
| ១ | ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង | ៣ |
| ២ | ការិយាល័យគ្រប់គ្រងធនធានមនុស្ស | ៣ |
| ៣ | ការិយាល័យលេខាធិការក្រុមប្រឹក្សា | ៣ |
| ៤ | ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ | ៣ |
| ៥ | ការិយាល័យអប់រំ យុវជន និងកីឡា | ៣ |
| ៦ | ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល | ៣ |
| ៧ | ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់ | ៣ |
| ៨ | ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន | ៣ |
| ៩ | អង្គភាពលទ្ធកម្ម | ៣ |
| ១០ | ការិយាល័យច្រកចេញចូលតែមួយ | ៣ |
| ១១ | ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ | ៣ |
| ១២ | ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម | ៣ |
| ១៣a | ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន (កម្រិតស្រុក) | ៣ |
| ១៣b | ការិយាល័យសាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ (កម្រិតក្រុង) | ៣ |
| ១៤ | អភិបាល | ១ |
| ១៥ | អភិបាលរង | ១ |
| ១៦ | នាយករដ្ឋបាល | ១ |
| ១៧ | នាយករងរដ្ឋបាល | ១ |
| | **សរុប** | **៤៦** |

[1] រដ្ឋបាលក្រុង ស្រុក ដែលស្របតាមគោលការណ៍នៃ "រដ្ឋបាលឯកភាព" ឬ "សមាហរណកម្ម" សំដៅទៅលើការរួមបញ្ចូលគ្នានូវរាល់ការិយាល័យជំនាញទាំងអស់ នៅរដ្ឋបាលក្រុង ស្រុក ឱ្យមកស្ថិតនៅក្រោមរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុកតែមួយ ដែលត្រូវដឹកនាំដោយអភិបាលតែម្នាក់ ដែលជាអ្នកទទួលខុសត្រូវចុងក្រោយ ទៅលើសមិទ្ធកម្មរបស់គ្រប់បុគ្គលិកទាំងអស់នៅក្នុងការិយាល័យទាំង ១៣ នៃរដ្ឋបាលក្រុង ស្រុក ដែលជាអតីតការិយាល័យជំនាញ។

## ៣. ការគាំទ្ររបស់ GIZ

GIZ បានគាំទ្រក្រសួងមុខងារសាធារណៈ ក្នុងការរៀបចំប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម តាំងពីក្នុងអំឡុងពេលអនុវត្តគម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវដ្ឋបាល (EU-DAR) ឆ្នាំ២០១៦-២០១៩ ហើយក៏បានបន្តកិច្ចសហការនេះរហូតមកដល់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវដ្ឋបាល (DAR) ដែលកំពុងធ្វើប្រតិបត្តិការរហូតដល់ពេលបច្ចុប្បន្ននេះ។

(១) គម្រោងសហភាពអឺរ៉ុបសម្រាប់គាំទ្រដល់កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវដ្ឋបាល (EU DAR)៖

- បានផ្តល់យោបល់ដល់ក្រសួងមុខងារសាធារណៈ ក្នុងការរៀបចំឯកសារណែនាំការសម្រាប់អនុវត្តស្តីពីប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ហើយស្របពេលគ្នានេះដែរ ក៏បានផ្តល់យោបល់ដល់ការិយាល័យច្រកចេញចូលតែមួយ (OWSO) នៅក្នុងស្រុកដៃគូនៃខេត្តបាត់ដំបងឱ្យបានដឹងអំពីប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម និងអនុវត្តសាកល្បងប្រព័ន្ធនេះនៅក្នុងការិយាល័យច្រកចេញចូលតែមួយ។
- ក្រសួងមុខងារសាធារណៈ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួងមហាផ្ទៃ បានឯកភាពឱ្យធ្វើការអនុវត្តសាកល្បង នូវឧបករណ៍ទាំងអស់របស់ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម នៅក្នុងការិយាល័យច្រកចេញចូលតែមួយ។ ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដែលទាមទារនូវថវិកាជាគ្រឿងលើកទឹកចិត្តដល់មន្ត្រីដែលមានសមិទ្ធកម្មឆ្នើម អាចអនុវត្តបាន នៅក្នុងការិយាល័យច្រកចេញចូលតែមួយ ដោយសារស្ថាប័ន នេះអាចប្រមូលចំណូល (ថ្លៃសេវា) មួយចំនួនបាន។ ការិយាល័យច្រកចេញចូលតែមួយនៃស្រុកមោងឫស្សី និងក្រុងបាត់ដំបង ត្រូវបានជ្រើសរើសសម្រាប់ការអនុវត្តសាកល្បងប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនេះ នៅឆ្នាំ២០១៨។ នៅឆ្នាំ២០១៩ ការវាយតម្លៃមួយត្រូវបានធ្វើឡើង ដោយទីប្រឹក្សាឯករាជ្យ ហើយបានបង្ហាញពីលទ្ធផលវិជ្ជមាននៃការអនុវត្តសាកល្បងនេះ។ ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃនេះ ក្រសួងមុខងារសាធារណៈ បច្ចុប្បន្នកំពុងធ្វើការបញ្ចុះបញ្ចូលទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើការវិភាជន៍ថវិកាជាតិមួយចំនួនសម្រាប់ការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មក្នុងទ្រង់ទ្រាយធំ។



*កិច្ចប្រជុំត្រួតពិនិត្យមើលសមិទ្ធកម្មឡើងវិញរវាងបុគ្គលិក និងអ្នកគ្រប់គ្រងនៃការិយាល័យច្រកចេញចូលតែមួយ (រូបភាព៖ មីន សាវ៉ាង, DAR)*

(២) កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវដ្ឋបាល (DAR) ដែលកំពុងធ្វើប្រតិបត្តិការរហូតដល់ពេលបច្ចុប្បន្ននេះ

- ការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ត្រូវបានពន្យារពេល ដោយសារតែការផ្លាស់ប្តូររដ្ឋមន្ត្រីនៃក្រសួងមុខងារសាធារណៈកាលពីខែមីនា ឆ្នាំ២០២០ ក៏ដូចជាការផ្លាស់ប្តូររចនាសម្ព័ន្ធ និងបុគ្គលិក។ ហេតុនេះហើយកិច្ចសហប្រតិបត្តិការនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវដ្ឋបាល បានផ្តោតទៅលើការរៀបចំការពិពណ៌នាមុខតំណែង

បែបទូទៅ។ បន្ថែមពីលើការរៀបចំការពិពណ៌នាមុខតំណែងបែបទូទៅចំនួន ៤៦ ដែលបានរៀបរាប់ខាងលើ GIZ ក៏បានគាំទ្រដល់ការរៀបចំការពិពណ៌នាមុខតំណែងបែបទូទៅសម្រាប់រដ្ឋបាលខណ្ឌផងដែរ។ "សេចក្តីព្រាងបឋមដំបូងបំផុត" នៃការពិពណ៌នាមុខតំណែងបែបទូទៅនេះ បច្ចុប្បន្នកំពុងត្រូវបានពិភាក្សា និងកែសម្រួល ដោយក្រុមការងារអន្តរក្រសួង។

- GIZ ក៏គាំទ្រក្រសួងមុខងារសាធារណៈផងដែរ ក្នុងការរៀបចំបញ្ចប់ឯកសារគតិយុត្តមួយចំនួន ដើម្បីជួយដល់ការរៀបចំ និងអនុម័តការពិពណ៌នាមុខតំណែង ឧទាហរណ៍ដូចជា ឯកសារណែនាំបច្ចេកទេស និងគំរូស្តង់ដារនៃការពិពណ៌នាមុខតំណែង ។ល។

giz

# ប័ណ្ណព័ត៌មាន៖ ការពង្រឹងយន្តការបណ្តឹងរដ្ឋបាល (ការិយាល័យប្រជាពលរដ្ឋ) នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

## ១. តើការិយាល័យប្រជាពលរដ្ឋ គឺជាអ្វី?

ក្នុងបរិបទទូទៅ **ការិយាល័យប្រជាពលរដ្ឋ** ឬ **អំប៊ុដស្មាន់ អំប៊ុដភីសិន** ឬ **អំប៊ុដ**[1] គឺជាមន្ត្រីដែលមានតួនាទីធ្វើជាតំណាងឱ្យផលប្រយោជន៍សាធារណៈដោយបំពេញភារកិច្ចស៊ើបអង្កេត និងដោះស្រាយបណ្តឹង ដែលទាក់ទិននឹងដំណើរការគ្រប់គ្រងរដ្ឋបាលមិនត្រឹមត្រូវ ឬក៏មានការរំលោភបំពានសិទ្ធិ។ វាមានដើមកំណើតនៅប្រទេសស៊ុយអែតនៅដើមសតវត្សទី១៩។ តួនាទីភារកិច្ចទូទៅរបស់អំប៊ុដភីសិន គឺការស៊ើបអង្កេតពាក្យបណ្តឹង ហើយបន្ទាប់មកគឺការព្យាយាមដោះស្រាយចំពោះបណ្តឹងទាំងនោះ ដែលជាធម្មតាតាមរយៈការផ្តល់ជាអនុសាសន៍ ឬការសម្រុះសម្រួលបណ្តឹង។ អំប៊ុដភីសិនត្រូវតែងតាំងដោយរដ្ឋាភិបាល ឬដោយរដ្ឋសភា ប៉ុន្តែត្រូវមានឯករាជ្យភាពគ្រប់គ្រាន់។

នៅក្នុងបរិបទនៃប្រទេសកម្ពុជា ការិយាល័យប្រជាពលរដ្ឋ ឬអំប៊ុដភីសិន នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ (DMK) ដែលហៅកាត់ថា DO គឺជាតំណាងរបស់ប្រជាពលរដ្ឋនៅក្នុងរដ្ឋបាល ដែលមានតួនាទីទទួលពាក្យបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋដែលគេយល់ឃើញថាមានភាពមិនប្រក្រតីទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ស៊ើបអង្កេតបណ្តឹង រាយការណ៍ ផ្តល់អនុសាសន៍ និងធ្វើការសម្រុះសម្រួលដោះស្រាយបណ្តឹងតវ៉ា។ ការិយាល័យប្រជាពលរដ្ឋ ត្រូវធានាថា ក្តីកង្វល់ ឬ បណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋត្រូវបានដោះស្រាយស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ការិយាល័យនេះ ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ និងការធានាឱ្យមានតម្លាភាព គណនេយ្យភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោត ក្នុងការផ្តល់សេវា និងក្នុងការគ្រប់គ្រងរដ្ឋបាល សាធារណៈ ហើយគាត់ក៏ជួយបង្កើតទំនាក់ទំនងល្អ និងទំនុកចិត្តរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយធុរកិច្ចជន និងប្រជាពលរដ្ឋផងដែរ។ ប្រធានការិយាល័យប្រជាពលរដ្ឋ ត្រូវបានបោះឆ្នោតជ្រើសរើសដោយគណៈកម្មាធិការបោះឆ្នោត ដែលមានសមាសភាពដូចជាសមាជិកសមាជិកាក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ដែលជ្រើសរើស តំណាងសហគមន៍ ធុរកិច្ចជន និងតំណាងអង្គការសង្គមស៊ីវិល។ ប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជាអាចបញ្ចេញមតិយោបល់ និងដាក់ពាក្យបណ្តឹងតវ៉ាទាក់ទិននឹង៖

- សេចក្តីសម្រេចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឬឃុំ សង្កាត់ (រដ្ឋបាលមូលដ្ឋាន) ដែលផ្ទុយនឹងគោលការណ៍ច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ឬដែលប៉ះពាល់ជាអវិជ្ជមានដល់ផលប្រយោជន៍បុគ្គល ឬសហគមន៍។
- ការបំពេញការងារ និងអាកប្បកិរិយារបស់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បុគ្គលិករបស់ក្រុមប្រឹក្សា បុគ្គលិករបស់រដ្ឋបាលមូលដ្ឋាន ឬ ភ្នាក់ងារទទួលសមត្ថកិច្ចក្នុងការផ្តល់សេវា។
- ការគ្រប់គ្រង និងការប្រើប្រាស់ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលមូលដ្ឋាន។
- ការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលមូលដ្ឋាន ឬ ភ្នាក់ងារទទួលសមត្ថកិច្ចក្នុងការផ្តល់សេវា។

[1] នៅក្នុងប្រទេសកម្ពុជា គេប្រើទាំងពីរពាក្យគឺ **អំប៊ុដស្មាន់** និង**ការិយាល័យប្រជាពលរដ្ឋ** ប៉ុន្តែដើម្បីជាការងាយស្រួល និងរក្សាអព្យាក្រឹតយេនឌ័រ កម្មវិធី GIZ/DAR ប្រើពាក្យ "អំប៊ុដភីសិន OMBUDSPERSON"

## ២. ស្ថានភាពជាក់ស្តែង និង តួលេខពិត

រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ឱ្យដំណើរការការិយាល័យប្រជាពលរដ្ឋ ដែលធ្វើសកម្មភាពដោយអព្យាក្រឹតក្នុងការទទួលបណ្តឹងតវ៉ាពីប្រជាពលរដ្ឋ និងសម្រុះសម្រួលដោះស្រាយចំនួនពីរដំបូងគេនៅក្នុងក្រុងបាត់ដំបង និងក្រុងសៀមរាប រួមជាមួយនឹងការិយាល័យច្រកចេញចូលតែមួយដែលមានតួនាទីផ្តល់សេវារដ្ឋបាល ក្នុងឆ្នាំ២០០៥ ហៅថា **ការិយាល័យប្រជាពលរដ្ឋ** ដើម្បីឱ្យពិនិត្យមើលការបំពេញការងារ ឬការផ្តល់សេវារបស់ការិយាល័យច្រកចេញចូលតែមួយ។

ជាបន្តបន្ទាប់ ការិយាល័យប្រជាពលរដ្ឋត្រូវបានដាក់ឱ្យដំណើរការនៅក្នុងក្រុងចំនួន២៤ ខណ្ឌចំនួន០៨ និងស្រុកចំនួន០២ នៅចន្លោះពេលពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤ ក្នុងអំឡុងពេលនៃការអនុវត្តគម្រោង DEMAND FOR GOOD GOVERNANCE PROJECT (DFGG) របស់ធនាគារពិភពលោក។ មកដល់ពេលបច្ចុប្បន្ននេះ មានការិយាល័យប្រជាពលរដ្ឋចំនួន១១៩ ត្រូវបានបង្កើតនៅថ្នាក់ក្រុង ស្រុក ខណ្ឌ (ស្មើនឹង៥៦ភាគរយនៃចំនួនក្រុង ស្រុក ខណ្ឌទាំងអស់ក្នុងប្រទេស)។ ក្នុងចំណោមការិយាល័យទាំងនេះ មានការិយាល័យចំនួន១៧ ដែលមានប្រធានការិយាល័យជាស្ត្រី។ ទន្ទឹមនឹងនេះ ការិយាល័យប្រជាពលរដ្ឋ ក៏ត្រូវបានបង្កើតឡើងនៅរដ្ឋបាលរាជធានី ខេត្ត ទាំង២៥ ផងដែរ។

នៅចុងឆ្នាំ២០១៩ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវអនុក្រឹត្យលេខ១៩ អនក្រ.បក ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ)។ អនុក្រឹត្យនេះបានផ្តល់តួនាទី ភារកិច្ច និងសិទ្ធិអំណាចបន្ថែមទៀតដល់ការិយាល័យប្រជាពលរដ្ឋក្នុងការដោះស្រាយបញ្ហានានាទាក់ទងនឹងការគ្រប់គ្រងរដ្ឋបាល និងការផ្តល់សេវារបស់រដ្ឋបាលមូលដ្ឋាន។

## ៣. ការគាំទ្ររបស់កម្មវិធី DAR

ក្នុងឆ្នាំ២០១៦ GIZ បានផ្តើមធ្វើកិច្ចការជាមួយនាយកដ្ឋានមុខងារ និងធនធាន នៃក្រសួងមហាផ្ទៃ ទាក់ទងនឹងយន្តការបណ្តឹងរដ្ឋបាល ហើយបានបង្កើនកិច្ចសហការនេះក្នុងអំឡុងពេលអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងរដ្ឋបាល (កម្មវិធី DAR) ដែលផ្តល់ហិរញ្ញប្បទានដោយក្រសួងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសហប្រតិបត្តិការនៃសហព័ន្ធអាល្លឺម៉ង់។

កម្មវិធី DAR បានរៀបចំឱ្យមានការផ្លាស់ប្តូរ និងការសិក្សាអំពីការអនុវត្តល្អៗពីគ្នាទៅវិញទៅមកក្នុងចំណោមការិយាល័យប្រជាពលរដ្ឋដែលមានវត្តមាននៅខេត្តបាត់ដំបង ដោយមានការពិភាក្សា និងការដោះស្រាយបញ្ហាប្រឈមនានាក្នុងការដោះស្រាយ បណ្តឹងរបស់ប្រជាពលរដ្ឋក្នុងខេត្តបាត់ដំបង។ លើសពីនេះ ទីប្រឹក្សាកម្មវិធីបានផ្តល់ការប្រឹក្សាយោបល់ជាប្រចាំដល់ប្រធានការិយាល័យប្រជាពលរដ្ឋ ដើម្បីឆ្លុះបញ្ចាំងអំពីការបំពេញការងារ និងស្វែងរកតម្រូវការអភិវឌ្ឍន៍សមត្ថភាពដើម្បីឱ្យពួកគេអនុវត្ត តួនាទី ភារកិច្ចកាន់តែប្រសើរឡើង។ វេទិកាផ្សព្វផ្សាយស្តីពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ការិយាល័យប្រជាពលរដ្ឋក៏ត្រូវបានរៀបចំឡើង ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានផងដែរ។

នៅចុងឆ្នាំ២០១៩ កម្មវិធី DAR បានសហការជាមួយនាយកដ្ឋានមុខងារ និងធនធាន ក្នុងការធ្វើការសិក្សាលម្អិតមួយដើម្បីស្វែងយល់អំពីស្ថានភាពនៃការអនុវត្តតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ។ របកគំហើញជាចម្បងបានបង្ហាញអំពីតម្រូវការដ៏ចាំបាច់ក្នុងការធ្វើឱ្យប្រសើរឡើងនូវល័ក្ខខ័ណ្ឌការងារសម្រាប់ប្រធានការិយាល័យប្រជាពលរដ្ឋ និងការកែសម្រួលក្របខ័ណ្ឌគតិយុត្ត ព្រមទាំងគោលការណ៍ណែនាំពាក់ព័ន្ធ។ បន្ថែមលើនេះ ការរកឃើញក៏បានបង្ហាញផងដែរថា ប្រជាពលរដ្ឋក្នុងមូលដ្ឋាន និងមន្ត្រីរាជការនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងនៅរដ្ឋបាលថ្នាក់ឃុំ សង្កាត់ មិនទាន់បានយល់ដឹងអំពីយន្តការ

នេះនៅឡើយ។ សិក្ខាសាលាស្តីពីតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ ត្រូវបានរៀបចំនៅក្នុងក្រុង ស្រុក ចំនួនប្រាំបួននៃខេត្តបាត់ដំបងដោយនាយកដ្ឋានមុខងារ និងធនធាន និងកម្មវិធី DAR ដើម្បីលើកកម្ពស់ការយល់ដឹងរបស់មន្ត្រីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ (មានអ្នកចូលរួមប្រមាណ ៦០០ នាក់ ក្នុងនោះក៏មានសមាជិក សមាជិកានៃក្រុមប្រឹក្សាក្រុង ស្រុក ផងដែរ)។ ចំណែកផ្នែកតម្រូវការនៃសេវាសាធារណៈ (ខាងប្រជាពលរដ្ឋ) កម្មវិធី DAR បានគាំទ្រដល់រដ្ឋបាលស្រុកចំនួនប្រាំក្នុងការរៀបចំការផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ និងអំពីរបៀបដាក់ បណ្តឹងតវ៉ា។



*រូបទី១៖ សៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងសម្រុះសម្រួលដោះស្រាយ ដែលគាំទ្រការបោះពុម្ពដោយកម្មវិធី DAR*

នាយកដ្ឋានមុខងារ និងធនធាន បានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំលើការអនុវត្តតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ក្នុងខែមករា ឆ្នាំ២០២១។ នៅក្នុងសិក្ខាសាលានេះ ប្រធានការិយាល័យប្រជាពលរដ្ឋមកពីគោលដៅទាំង១១៥ បានផ្តល់ការឯកភាពជាឯកច្ឆ័នលើបញ្ជីអនុសាសន៍ ដែលបានរៀបចំឡើងក៏ដូចជាអនុសាសន៍ដែលបានដកស្រង់ចេញពី របាយការណ៍នៃការសិក្សាលម្អិត អំពីស្ថានភាពនៃការអនុវត្តតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋ និងបានស្នើឱ្យនាយកដ្ឋានមុខងារ និងធនធាន ក៏ដូចជាក្រសួងមហាផ្ទៃ ចាត់វិធានការចាំបាច់ ដូចជា ធ្វើការកែសម្រួលលិខិតបទដ្ឋានគតិយុត្ត និងកែលម្អល័ក្ខខ័ណ្ឌការងារសម្រាប់ប្រធានការិយាល័យប្រជាពលរដ្ឋ។ ជាការឆ្លើយតបទៅនឹងលទ្ធផលនៃការសិក្សាលម្អិត និងលទ្ធផលនៃសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានដាក់ចេញលិខិតលេខ ១៩៤៩ ស.ជ.ណស្តីពីការពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។

កម្មវិធី DAR កំពុងធ្វើការជាមួយនាយកដ្ឋានមុខងារ និងធនធាន ដោយសហការជាមួយអង្គការតម្លាភាពអន្តរជាតិ-កម្ពុជា ក្នុងការរៀបចំចងក្រងសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលសម្រាប់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ និងចងក្រងសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបណ្តឹងសម្រាប់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

បន្ថែមទៅលើកិច្ចការអភិវឌ្ឍន៍សមត្ថភាព កម្មវិធី DAR បានផ្តល់សម្ភារប្រើប្រាស់ ដូចជា ម៉ាស៊ីនកុំព្យូទ័រ បរិក្ខាអេឡិចត្រូនិចដែលចាំបាច់ ដល់ការិយាល័យប្រជាពលរដ្ឋចំនួនប្រាំបួននៅក្នុងខេត្តបាត់ដំបង ដើម្បីឱ្យពួកគេអាចចូលរួមក្នុងកិច្ចប្រជុំតាមប្រព័ន្ធបញ្ជូនរូបភាពនិងសំឡេង និងអាចចូលរួមក្នុងការបណ្តុះបណ្តាលផ្សេងៗពីចម្ងាយបាន ជាពិសេសក្នុងអំឡុងពេលមានការឆ្លងរាលដាលនៃមេរោគកូវីដ-១៩ ខណៈដែលការធ្វើដំណើរ និងការជួបជុំដោយផ្ទាល់ត្រូវបានកម្រិត។




*រូបទី២៖ ផ្ទាំងប៉ាណូអំពីការិយាល័យប្រជាពលរដ្ឋសម្រាប់ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋអំពី៖ តើ "ការិយាល័យប្រជាពលរដ្ឋ"ជាអ្វី តើប្រជាពលរដ្ឋអាចដាក់បណ្តឹងតវ៉ាអំពីបញ្ហាអ្វីខ្លះ ព្រមទាំងលេខទូរស័ព្ទសម្រាប់ទំនាក់ទំនង ក៏ដូចជាពេលម៉ោងធ្វើការរបស់ការិយាល័យនេះដែរ*

# ប័ណ្ណព័ត៌មានៈ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក)

## ១. តើអ្វីទៅជាគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ?

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) ជាគណៈកម្មាធិការមួយក្នុងចំណោមគណៈកម្មាធិការកាតព្វកិច្ចទាំងបីរបស់ក្រុមប្រឹក្សា។ គ.ក.ស.ក មានតួនាទី និងទទួលខុសត្រូវដូចជាៈ

១) ផ្តល់មតិយោបល់ និងអនុសាសន៍ក្នុងការអភិវឌ្ឍន៍ទាក់ទងនឹងសមភាពយេនឌ័រ និងបញ្ហានានារបស់ស្ត្រី យុវជន និងកុមារ

២) សម្របសម្រួល និងស្វែងរកការគាំទ្រដើម្បីដាក់បញ្ចូលសកម្មភាពនានាទៅក្នុងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សា

៣) ចូលរួមក្នុងការប្រមូល វិភាគ និងរាយការណ៍ព័ត៌មាន និងទិន្នន័យទាក់ទងសមភាពយេនឌ័រ និងបញ្ហារបស់ស្ត្រី យុវជន និងកុមារ

នៅខែធ្នូ ឆ្នាំ២០១៩ រដ្ឋាភិបាលកម្ពុជា បានអនុម័តនូវអនុក្រឹត្យលេខ១៨២ ១៨៣ និង១៨៤ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់ទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ នេះបង្ហាញថាតួនាទី និងការទទួលខុសត្រូវរបស់ គ.ក.ស.ក មានការកើនឡើងដោយសារក្រុមប្រឹក្សាស្រុកត្រួតពិនិត្យសកម្មភាពរដ្ឋបាលស្រុក ដែលមានតួនាទី ភារកិច្ច និងការទទួលខុសត្រូវកើនឡើងច្រើនដោយផ្អែកតាមអនុក្រឹត្យនេះ។ ដូច្នេះហើយ ការពង្រឹងសមត្ថភាពដល់ គ.ក.ស.ក ដើរតួសំខាន់ណាស់ក្នុងការផ្តល់សិទ្ធិអំណាចដល់សមាជិករបស់ គ.ក.ស.ក ក្នុងការបញ្ចេញសំឡេងរបស់ពួកគេនៅក្នុងកិច្ចប្រជុំសាធារណៈ និងនាំយកបញ្ហា និងកង្វល់របស់ប្រជាពលរដ្ឋមកពិភាក្សានៅក្នុងកិច្ចប្រជុំប្រចាំខែរបស់គ.ក.ស.ក ដើម្បីស្វែងរកដំណោះស្រាយលើបញ្ហា និងកង្វល់ទាំងនោះ។ ដូច្នេះ ការពង្រឹងសិទ្ធិអំណាច ដល់ គ.ក.ស.ក ពិតជាមានសារៈសំខាន់ណាស់ ព្រោះវាជាមូលដ្ឋានគ្រឹះសម្រាប់ក្រុមប្រឹក្សាធ្វើសេចក្តីសម្រេចចិត្ត។

## ២. ស្ថានភាពជាក់ស្តែង និងតួលេខពិត

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ដឹកនាំដោយប្រធាន ឬអនុប្រធាន ដែលជាសមាជិកក្រុមប្រឹក្សាស្ត្រី និងដែលត្រូវបានជ្រើសរើសសម្រាប់អាណត្តិបួនឆ្នាំ។ ប្រសិនបើមិនមានសមាជិកក្រុមប្រឹក្សាស្ត្រីនៅក្នុងក្រុមប្រឹក្សាទេនោះ អភិបាលរងស្ត្រីនឹងត្រូវបានជ្រើសរើសជាប្រធាន គ.ក.ស.ក ។ គ.ក.ស.ក រៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយចំពោះបញ្ហាស្ត្រី និងកុមារ។ បន្ទាប់មក គ.ក.ស.ក លើកបញ្ហាពាក់ព័ន្ធទាំងនោះនៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា។ នៅពេលដែលក្រុមប្រឹក្សាឯកភាពក្នុងការដោះស្រាយបញ្ហាដែលលើកឡើងដោយ គ.ក.ស.ក និងធ្វើការសម្រេចចិត្តរួច រដ្ឋបាលស្រុក ឬ ក្រុង ត្រូវអនុវត្តការសម្រេចចិត្តរបស់ក្រុមប្រឹក្សា។ គ.ក.ស.ក មានភារកិច្ចប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យទាក់ទងនឹងសមិទ្ធផលទាក់ទិននឹងសមភាពយេនឌ័រ និងបញ្ហា និងតម្រូវការរបស់ស្ត្រី និងកុមារ ក៏ដូចជាបញ្ចូលព័ត៌មាននេះទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិល (ជាផ្នែកនៃផែនការ ៥ ឆ្នាំ) របស់ស្រុក ឬ ក្រុង (DM)។ គ.ក.ស.ក ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់យោបល់ និងអនុសាសន៍ដល់ក្រុមប្រឹក្សា ឬ គណៈអភិបាល អំពីវិធានការសមស្រប ដើម្បីដោះស្រាយបញ្ហា និងទប់ស្កាត់គ្រោះថ្នាក់ដែលអាចកើតឡើងដល់ស្ត្រី យុវជន និងកុមារ។ គ.ក.ស.ក

តាមដានការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវជន និងកុមារ ជាពិសេសដើម្បីកំណត់ពីវិសមភាពក្នុងការទទួលបានសេវា និងផ្តល់អនុសាសន៍ដើម្បីកាត់បន្ថយ/លុបបំបាត់វិសមភាពនេះ។ គណៈកម្មាធិការនេះ លើកកម្ពស់ទំនាក់ទំនង កិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាប្រភេទផ្សេងគ្នា ការិយាល័យជំនាញនានា ភ្នាក់ងារផ្តល់សេវា អង្គការក្រៅរដ្ឋាភិបាល ក្រុមអ្នកស្ម័គ្រចិត្ត និងសហគមន៍ ដើម្បីធានាថារាល់សកម្មភាពទាក់និងស្ត្រី យុវជន និងកុមារត្រូវបានអនុវត្ត។ តួនាទីរបស់ប្រធាន គ.ក.ស.ក គឺរៀបចំកិច្ចប្រជុំប្រចាំខែជាមួយសមាជិកទាំងអស់ដែលតំណាងឱ្យការិយាល័យពាក់ព័ន្ធ និងស្ត្រីជាជនបង្គោលពីថ្នាក់ឃុំ។ កិច្ចប្រជុំទាំងនោះ រៀបចំឡើង ដើម្បីធ្វើបច្ចុប្បន្នភាព និងចែករំលែកព័ត៌មានពីឃុំផ្សេងៗ និងនាំយកបញ្ហានានាមកពិភាក្សាក្នុងចំណោមគណៈកម្មាធិការទាំងមូលនៅថ្នាក់ស្រុក និងស្វែងរកដំណោះស្រាយដើម្បីឆ្លើយតបនឹងតម្រូវការប្រជាពលរដ្ឋ។ តួនាទីទីពីររបស់ប្រធានគណៈកម្មាធិការ គឺការផ្លាស់ប្តូរជាមួយសមាជិកអចិន្ត្រៃយ៍ដើម្បីកៀរគរធនធាន។ តួនាទីទីបីរបស់ប្រធានគណៈកម្មាធិការ គឺរាយការណ៍ពីលទ្ធផលនៃកិច្ចប្រជុំទៅក្រុមប្រឹក្សាស្រុកក្នុងអំឡុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា ដើម្បីស្វែងរកការគាំទ្រមតិក្នុងការដោះស្រាយកង្វល់នានា និងស្វែងរកការគាំទ្រពីក្រុមប្រឹក្សាស្រុក។

ដ្យាក្រាមខាងក្រោមបង្ហាញពីរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលឯកភាពរបស់ក្រុង ស្រុក។ នៅក្នុងខេត្តបាត់ដំបង មានគណៈកម្មាធិការចំនួន ១៥ រួមទាំងថ្នាក់ក្រុង និងថ្នាក់ខេត្ត។ គណៈកម្មាធិការនីមួយៗមានសមាជិកចន្លោះពី ២២ ទៅ ២៧ នាក់ (ប្រុស និងស្រី) អាស្រ័យលើរចនាសម្ព័ន្ធរដ្ឋបាលរបស់ ក្រុង ស្រុក និងជាពិសេសចំនួនឃុំ/សង្កាត់។ សមាជិក គ.ក.ស.ក ជាតំណាងមកពីការិយាល័យជំនាញក្រុង ស្រុក និងជាតំណាងមកពីឃុំ/សង្កាត់នីមួយៗរបស់ក្រុង ស្រុក។ គ.ក.ស.ក. ថ្នាក់ខេត្ត មានសមាជិកក្រុមប្រឹក្សាស្ត្រីចំនួន ៥រូប ចំណែកក្រុង ស្រុកទាំង ១៤ មានសមាជិកក្រុមប្រឹក្សាស្ត្រីចំនួន ៦៣រូប។

# រចនាសម្ព័ន្ធរដ្ឋបាលស្រុក



## ៣. ការគាំទ្ររបស់ GIZ

ការពង្រឹងសំឡេងសមាជិកក្រុមប្រឹក្សាស្ត្រី និង គ.ក.ស.ក និងការបង្កើនឥទ្ធិពល និងប្រសិទ្ធភាពរបស់ គ.ក.ស.ក នៅក្នុងក្រុមប្រឹក្សាក្រុង ស្រុក ជួយបង្កើនការចូលរួមផ្នែកនយោបាយ និងឥទ្ធិពលរបស់ស្ត្រីក្នុងជីវិតសាធារណៈក្នុងរយៈពេលវែង។ GIZ ពង្រឹងសមត្ថភាពរបស់ គ.ក.ស.ក ក្នុងការបង្កើនប្រសិទ្ធភាពនៃសំណើរបស់ខ្លួនក្នុងនីតិវិធីនៃការសម្រេចចិត្ត និងប្រាកដថាសំណើរបស់ប្រជាពលរដ្ឋត្រូវបានពិចារណាគ្រប់គ្រាន់ដោយអ្នកតំណាងជាប់ឆ្នោត។ ខាងក្រោមនេះជាសេចក្តីសង្ខេបនៃសកម្មភាពសំខាន់ៗ៖

**(១) កម្មវិធីសហភាពអឺរ៉ុប ដើម្បីលើកកម្ពស់ការបំពេញការងារ គណនេយ្យភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ (EU SPACE) ២០១៣– ២០១៦ និងកម្មវិធីសហភាពអឺរ៉ុប ដើម្បីគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិមជ្ឈបាល (EU DAR)២០១៦ – ២០១៩**

- ដោយពិគ្រោះយោបល់ជាមួយ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) និងក្រសួងកិច្ចការនារី GIZ បានចុះកិច្ចសន្យាជាមួយអង្គការក្រៅរដ្ឋាភិបាល ចំនួនប្រាំ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់សមាជិកក្រុមប្រឹក្សាស្ត្រីទាំងអស់នៅថ្នាក់ខេត្ត ក្រុង និងស្រុកទូទាំងប្រទេស[1] ។
- សិក្ខាសាលាចែករំលែកចំណេះដឹង និងចងក្រងបណ្តាញ ត្រូវបានរៀបចំឡើងដោយ គ.ជ.អ.ប សម្រាប់សមាជិកក្រុមប្រឹក្សាស្ត្រី ហើយវគ្គបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សាស្ត្រីទូទាំងប្រទេស ត្រូវបានផ្តល់ជាបន្តបន្ទាប់ ពីព្រោះក្រុមប្រឹក្សាស្ត្រីជាច្រើននាក់ដែលទើបជាប់ឆ្នោតថ្មី មិនទាន់មានបទពិសោធន៍ក្នុងការបំពេញការងាររបស់គេក្នុងនាមជាក្រុមប្រឹក្សា។

**(២) កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិមជ្ឈបាល (DAR)**

ដើម្បីពង្រឹងទំនុកចិត្តរបស់សមាជិកគណៈកម្មាធិការ GIZ គាំទ្រ គ.ក.ស.ក ក្នុងខេត្តបាត់ដំបង តាមរយៈការផ្តល់ប្រឹក្សាយោបល់ជាប្រចាំដើម្បីកំណត់បញ្ហា និងរៀបចំ និងអនុវត្តដំណោះស្រាយបញ្ហា។ GIZ បានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសលើបញ្ហាដែលបានលើកឡើង និងធនធានហិរញ្ញវត្ថុតាមរយៈគម្រោងកិច្ចព្រមព្រៀងឧបត្ថម្ភធនរបស់ GIZ ដើម្បីសម្របសម្រួលដោះស្រាយបញ្ហាដែលបានលើកឡើង និងដើម្បីបង្កើនជំនាញគ្រប់គ្រងរបស់ក្រុមប្រឹក្សាស្ត្រី ។

វគ្គបណ្តុះបណ្តាលជាស៊េរីបានរៀបចំឡើងលើប្រធានបទដូចខាងក្រោម៖

- វគ្គបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំ និងការពង្រឹងសិទ្ធិអំណាចដល់ស្ត្រី ដល់ប្រធាន និងអនុប្រធាន គ.ក.ស.ក ទាំង០៦ (ប្រាំមួយ) ស្រុក និងក្រុងនៃខេត្តគោលដៅរបស់កម្មវិធី DAR។
- វគ្គបណ្តុះបណ្តាលចំនួនបីផ្សេងបានផ្តល់ជូនសមាជិក គ.ក.ស.ក៖ (១) ការប្រមូលទិន្នន័យ ការសរសេរសំណើ និងការកៀរគរធនធាន (២) ការស្វែងរកការគាំទ្រមតិ និង (៣) ការប្រឹក្សាយោបល់ជាមូលដ្ឋាន។ បន្ទាប់មកសមាជិក គ.ក.ស.ក មួយចំនួនត្រូវបានជ្រើសរើសឱ្យចូលរួម វគ្គបណ្តុះបណ្តាលគ្រូបង្គោលដើម្បីអាចឱ្យពួកគេបណ្តុះបណ្តាលបន្តដល់សមាជិកថ្មីដែលនឹងជាប់ឆ្នោតនាពេលអនាគត។

[1] វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API), VBNK, អង្គការសីលការ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GAD/C) និងអង្គការស្តារកម្ពុជា